**បេឡាជាតិរបបសន្តិសុខសង្គម**

**NATIONAL SOCIAL SECURITY FUND**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ ២០១៦
# និងទិសដៅអនុវត្តបន្ត

"ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" រួមមាន៖

☆ ផ្នែកហានិភ័យការងារ ☆ ផ្នែកថែទាំសុខភាព ☆ ផ្នែកប្រាក់សោធន

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម

បេឡាជាតិរបបសន្តិសុខសង្គម

NATIONAL SOCIAL SECURITY FUND

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារសម្រេចបាន ឆ្នាំ២០១៦
## និងទិសដៅអនុវត្តបន្ត

"ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" រួមមាន៖

- ★ ផ្នែកហានិភ័យការងារ
- ★ ផ្នែកថែទាំសុខភាព
- ★ ផ្នែកប្រាក់សោធន

# មាតិកា


**-ចក្ខុវិស័យ បេសកកម្ម និងគោលដៅ**.......................................................I

**-អគ្គការលេខរបស់ ប.ស.ស**.......................................................II

I. **សេចក្តីផ្តើម**.......................................................១

II. **លទ្ធផលការងារសម្រេចបានឆ្នាំ២០១៦**.......................................................២

**១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**.......................................................២

១.១. ការងារបញ្ជិកា និងភាគទាន.......................................................២

១.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម.......................................................៧

១.៣. ការងារតាវកាលិក.......................................................៩

១.៤. ការងាររៀបចំបុននីតិសម្បទា.......................................................១៥

**២. ការរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**.......................................................១៦

២.១. ការងារបញ្ជិកា និងភាគទាន.......................................................១៧

២.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម.......................................................១៨

២.៣. ការផ្តល់សេវាតាវកាលិក.......................................................១៨

**៣. ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**.......................................................១៩

**៤. ការងារគាំទ្រការអនុវត្ត**.......................................................១៩

៤.១. ការងាររៀបចំគោលនយោបាយ និងលិខិតគតិយុត្ត.......................................................១៩

៤.២. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស.......................................................២០

៤.២.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ.......................................................២០

៤.២.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស.......................................................២២

៤.២.៣. ការងារព័ត៌មានវិទ្យា.......................................................២៧

៤.២.៤. ការងារសវនកម្មផ្ទៃក្នុង.......................................................៣៤

៤.២.៥. គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម.......................................................៣៤

៤.៣. ការងារប្រជុំផ្សព្វផ្សាយ និងបង្ការហានិភ័យការងារ.......................................................៣៥

៤.៣.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម.......................................................៣៦

៤.៣.២. ក្រុមការងារ ប.ស.ស សហការជាមួយក្រុមការងារផ្សព្វផ្សាយពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ.......................................................៣៧

៤.៣.៣. ការងារប្រជុំផ្សព្វផ្សាយបង្ការហានិភ័យការងារ.......................................................៣៧

៤.៣.៣.១. ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ.......................................................៣៧

៤.៣.៣.២. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត.......................................................៣៩

III. **បញ្ហាប្រឈម**.......................................................៤១

IV. **ការដោះស្រាយ និងទិសដៅអនុវត្តបន្ត**.......................................................៤៣

V. **សេចក្តីសន្និដ្ឋាន**.......................................................៤៥

-លទ្ធផលសម្រេចបានធៀប នឹងផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៤-២០១៨.......................................................៤៧

-ការិយាល័យសាខាបេឡាជាតិរបបសន្តិសុខសង្គមតាមរាជធានី-ខេត្ត.......................................................៥៩

- ***ឧបសម្ព័ន្ធ***


- ចំនួនសហគ្រាស គ្រឹះស្ថានចុះបញ្ជិកាតាមខែ និងតាមរាជធានី-ខេត្ត..........៦១
- ចំនួនសហគ្រាសចុះបញ្ជិកា និងកម្មករនិយោជិតតាមរាជធានី-ខេត្ត..........៦២
- បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត..........៦៣
- បច្ចុប្បន្នភាពសហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើងថ្នាក់កណ្តាល/ថ្នាក់ខេត្ត..........៦៤
- ប្រភេទ និងចំនួនសហគ្រាស គ្រឹះស្ថានបានចុះបញ្ជិកា..........៦៥
- ចំនួនសហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល/ថ្នាក់ខេត្ត..........៦៨
- របាយការណ៍ហានិភ័យការងារ និងលទ្ធផលអង្កេត..........៦៩
- ស្ថានភាពហានិភ័យការងារ តាមរាជធានី-ខេត្ត..........៧០
- លទ្ធផលអង្កេតហានិភ័យការងារ តាមរាជធានី-ខេត្ត..........៧១
- តារាងចំណាត់ថ្នាក់ហានិភ័យការងារ..........៧២

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ធានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

## គោលដៅ

១. ពង្រីក និងពង្រឹងការអនុវត្តផ្នែកហានិភ័យការងារ (គ្រោះថ្នាក់នៅកន្លែងធ្វើការ, គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ)

២. ដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព (សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ, សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះនិងសេវាបញ្ជូនសព, ប្រាក់បំណាច់ប្រចាំថ្ងៃ និងសេវាបង្ការសុខភាព)

៣. ដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន (ជរាភាព, ទុព្វលភាព, មរណភាព)

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម ( ប.ស.ស )



# របាយការណ៍
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧
# របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

## I. សេចក្តីផ្តើម

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ, ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ត្រូវបានអនុវត្តអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងអនុក្រឹត្យស្តីពីការបង្កើត ប.ស.ស ដោយស្របតាមយុទ្ធសាស្ត្រចតុកោណ, យុទ្ធសាស្ត្រអភិវឌ្ឍជាតិ, យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំ-ពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

អនុលោមតាមច្បាប់ និងផែនការយុទ្ធសាស្ត្រខាងលើ ប.ស.ស បានដាក់ផែនការអនុវត្តជំហានទី១ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ព្រមទាំងទទួលបានការគាំទ្រទាំងនៅកំរិតថ្នាក់ជាតិ និងអន្តរជាតិ។ មួយវិញទៀត ប.ស.ស ក៏បាននិងកំពុងអនុវត្តជំហានទី២ របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ជូនដល់កម្មករនិយោជិត ដោយអនុលោមទៅតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ក្នុងរយៈពេល ៨ ឆ្នាំ គិតចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៦ ការដាក់ឱ្យដំណើរការជំហានទី១ ផ្នែកហានិភ័យការងារ ដែលទទួលបានជោគជ័យនេះ វាជាចលករដ៏សំខាន់មួយទៀតក្នុងការជួយជម្រុញឱ្យ ប.ស.ស មានបទពិសោធន៍ប្រកបដោយសក្តានុពល ដើម្បីបង្កើតផ្នែកថ្មីៗបន្ថែមទៀត សំដៅចូលរួមសម្រាលទុក្ខលំបាកនានារបស់សមាជិកសង្គម ក៏ដូចជាចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ និងលើកកម្ពស់ស្ថិរភាពសង្គម។ ទន្ទឹមនឹងភាពជោគជ័យនេះ ប.ស.ស ក៏បានរកឃើញនូវបញ្ហាមួយចំនួនផងដែរទាំងចំណុចខ្លាំង និងចំណុចខ្សោយ ដែលជាបទពិសោធន៍ដ៏មានសារៈសំខាន់មួយទៀត សម្រាប់ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តជំហានទី១ និងការអនុវត្តជំហានទី២ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ជូនដល់កម្មករនិយោជិត ក្នុងទិសដៅលើកកម្ពស់សុខភាពកម្មករនិយោជិត និងជំហានទី៣ ផ្នែកប្រាក់សោធន ក្នុងទិសដៅរួមចំណែកលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ជនចាស់ជរា ដែលនេះជាមោទនភាពជាតិក្នុងសម័យតេជោ ដែលបង្កើតឱ្យមានក្នុងគោលបំណងការពារបងប្អូនពេលចាស់ជរា ធ្វើការមិនកើត ដើម្បីឱ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ព្រមទាំងរបបប្រាក់សោធនឱ្យបានដូចមន្ត្រីរាជការផងដែរ។

ប.ស.ស សង្ឃឹមយ៉ាងមុតមាំថា របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបាន ឆ្នាំ២០១៦ នេះ វានឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់វាស់វែងតាមដាន និងវាយតម្លៃលើការអនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ហើយវាជាកញ្ចក់

ឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងបញ្ហាប្រឈមនានា ដើម្បីធ្វើការកែតម្រូវ និងធ្វើការដោះស្រាយ សម្រាប់រៀបចំទិសដៅអនុវត្តបន្ត ឱ្យបានកាន់តែល្អប្រសើរថែមទៀត។

## II. លទ្ធផលការងារសម្រេចបានឆ្នាំ២០១៦

### ១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

#### ១.១. ការងារបញ្ជិកា និងភាគទាន

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបង់ភាគទានហានិភ័យការងារមកក្នុង ប.ស.ស។ ក្នុងដំណាក់កាលចាប់ដំណើរការដំបូងនៃ ប.ស.ស ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថាន ណាដែលមានកម្មករនិយោជិតចំនួន ០៨ នាក់ឡើង។ អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាព ដែលត្រូវបានកំណត់ស្មើនឹង ០,៨ ភាគរយ នៃប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

*រូបភាពទី១. សកម្មភាពនៃការចុះបញ្ជិកា និង បង់ភាគទាននៅ ប.ស.ស*



##### ១.១.១. ការងារចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

ចាប់តាំងពីដំណើរការដំបូងនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ឆ្នាំ២០១៦ នេះ ប.ស.ស បានពង្រីកវិសាលភាពផ្នែកហានិភ័យការងារ គ្របដណ្តប់នៅទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សរុបចំនួន ៨.៧៣១សហគ្រាស មានកម្មករនិយោជិតសរុបចំនួន *១.១៣៦.២៧១* នាក់ ស្រីចំនួន *៧៩៨.០២៧* នាក់ ត្រូវជា *៧០,២៣* ភាគរយ។

ដោយឡែកសម្រាប់ឆ្នាំ២០១៦ នេះ ប.ស.ស បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត តាមបណ្តារាជធានី-ខេត្ត បានចំនួន *៩៣៥* សហគ្រាស និងមានកម្មករ-និយោជិតចំនួន *៥៩.១៩២* នាក់ ស្រី *៣៦.០១៤* នាក់ ក្នុងនោះរាជធានីភ្នំពេញមានចំនួន *៤២៦* សហគ្រាស មានកម្មករនិយោជិត ចំនួន *២៤.៩៦៩*នាក់ ស្រីចំនួន *១៤.៤២៥*នាក់ និងថ្នាក់ខេត្តមានចំនួន *៥០៩*សហគ្រាស

មានកម្មករនិយោជិតចំនួន *៣៤.២២៣* នាក់ ស្រីចំនួន *២១.៥៨៩* នាក់។

*ក្រាហ្វិកទី១. ស្ថានភាពសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាតាមរាជធានី-ខេត្ត ឆ្នាំ២០១៦ (ទិន្នន័យលំអិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី១)*




**តារាងទី ១.សហគ្រាសចុះបញ្ជិកា និងសមាជិកថ្នាក់កណ្តាល/ថ្នាក់ខេត្ត**

**សហគ្រាសចុះបញ្ជិកា និងសមាជិកសរុប**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2008-ឆ្នាំ2016 | 8,731 | 1,136,271 | 798,027 | 5,113 | 646,506 | 434,755 | 3,618 | 489,765 | 363,272 |
| ឆ្នាំ2008-ឆ្នាំ2015 | 7,796 | 1,077,079 | 762,013 | 4,687 | 621,537 | 420,330 | 3,109 | 455,542 | 341,683 |
| បម្រែបម្រួល (± %) | +11.99% | +5.50% | +4.73% | +9.09% | +4.02% | +3.43% | +16.37% | +7.51% | +6.32% |

**សហគ្រាសចុះបញ្ជិកា និងសមាជិកថ្មី**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2016 | 935 | 59,192 | 36,014 | 426 | 24,969 | 14,425 | 509 | 34,223 | 21,589 |
| ឆ្នាំ2015 | 755 | 55,491 | 36,686 | 388 | 31,426 | 20,640 | 367 | 24,065 | 16,046 |
| បម្រែបម្រួល (± %) | +23.84% | +6.67% | -1.83% | +9.79% | -20.55% | -30.11% | +38.69% | +42.21% | +34.54% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ២)

**តារាងទី ២. បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

**បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2016 | 6,884 | 1,108,759 | 752,459 | 3,832 | 611,064 | 396,987 | 3,052 | 497,695 | 355,472 |
| ឆ្នាំ2015 | 6,470 | 1,109,890 | 779,998 | 3,766 | 638,583 | 424,726 | 2,704 | 471,307 | 355,272 |
| បម្រែបម្រួល (± %) | +6.40% | -0.10% | -3.53% | +1.75% | -4.31% | -6.53% | +12.87% | +5.60% | +0.06% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៣)

**តារាងទី ៣. បច្ចុប្បន្នភាព សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង ថ្នាក់កណ្តាល -ថ្នាក់ខេត្ត**

**សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង ថ្នាក់កណ្តាល -ថ្នាក់ខេត្ត**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហ | សមាជិក | ស្រី | សហ | សមាជិក | ស្រី |
| ឆ្នាំ2016 | 1,006 | 687,686 | 566,645 | 646 | 362,001 | 298,371 | 360 | 325,685 | 268,274 |
| ឆ្នាំ2015 | 1,088 | 715,640 | 599,158 | 733 | 405,158 | 333,768 | 355 | 310,482 | 265,390 |
| បម្រែបម្រួល (± %) | -7.54% | -3.91% | -5.43% | -11.87% | -10.65% | -10.61% | +1.41% | +4.90% | +1.09% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៤)

### ១.១.២. ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា

ក្នុងឆ្នាំ២០១៦ នេះ ប.ស.ស បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ចំនួន *៩៣៥* ក្នុងនោះវិស័យសណ្ឋាគារមានចំនួនច្រើនជាងគេ *៧០*, ភោជនីយដ្ឋាន *៦៣*, កាត់ដេរ *៦២*, ភ្នាក់ងារដឹក-ជញ្ជូន ៥៦, អង្គការក្រៅរដ្ឋាភិបាល ៥០ និងសហគ្រាសផ្សេងៗទៀតចំនួន *៦៣៤* ។ *(ទិន្នន័យលំអិតសូមអានក្នុងតារាងឧបសម្ព័ន្ធទី៥)*

*ក្រាហ្វិកទី២. ប្រភេទសហគ្រាសបានចុះបញ្ជិកា ឆ្នាំ២០១៦*




### ១.១.៣. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ

*តារាងទី ៤. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល -ថ្នាក់ខេត្ត*

| សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល-ថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | បិទទ្វារ | | | ផ្អាកដំណើរការ | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2016 | 614 | 60,191 | 41,295 | 525 | 51,536 | 34,925 | 89 | 8,655 | 6,370 |
| ឆ្នាំ2015 | 470 | 35,387 | 16,515 | 367 | 30,019 | 13,377 | 103 | 5,368 | 3,138 |
| **បម្រែបម្រួល (± %)** | +30.64% | +70.09% | +150.05% | +43.05% | +71.68% | +161.08% | -13.59% | +61.23% | +103.00% |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៦)**

*តារាងទី ៤.១. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល*

| សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | បិទទ្វារ | | | ផ្អាកដំណើរការ | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2016 | 419 | 37,235 | 24,711 | 367 | 32,116 | 20,880 | 52 | 5,119 | 3,831 |
| ឆ្នាំ2015 | 293 | 24,235 | 11,169 | 242 | 21,570 | 9,559 | 51 | 2,665 | 1,610 |
| **បម្រែបម្រួល (± %)** | +43.00% | +53.64% | +121.25% | +51.65% | +48.89% | +118.43% | +1.96% | +92.08% | +137.95% |

*តារាងទី ៤.២. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់ខេត្ត*

| សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | បិទទ្វារ | | | ផ្អាកដំណើរការ | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2016 | 195 | 22,956 | 16,584 | 158 | 19,420 | 14,045 | 37 | 3,536 | 2,539 |
| ឆ្នាំ2015 | 177 | 11,152 | 5,346 | 125 | 8,449 | 3,818 | 52 | 2,703 | 1,528 |
| **បម្រែបម្រួល (± %)** | +10.17% | +105.85% | +210.21% | +26.40% | +129.85% | +267.86% | -28.85% | +30.82% | +66.16% |

ជាការគួរឱ្យកត់សំគាល់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ដែលបានឈប់ដំណើរការខាងលើរហូតមកដល់ពេលនេះ មានសហគ្រាស គ្រឹះស្ថាន មួយចំនួនបានបើកដំណើរការឡើងវិញហើយ ដែលក្នុងនោះមួយចំនួនបានប្តូរឈ្មោះ មួយចំនួនទៀតបានប្តូរម្ចាស់ ដែលភាគច្រើនជាសិប្បកម្ម, ឡេតដ្ឋ, ភោជនីយដ្ឋាន ,.....ដែលមានទីតាំងនៅឆ្ងាយ។

### ១.១.៤. ប្រៀបធៀបការងារចុះបញ្ជិកា

*ក្រាហ្វិកទី៣. ការងារចុះបញ្ជិកាគិតត្រឹម ឆ្នាំ២០១៥ និងឆ្នាំ២០១៦*




ផ្អែកតាមក្រាហ្វិចនេះ សហគ្រាសមានការកើនឡើង ៩៣៥ សហគ្រាស ស្មើនឹង ១១,៩៩ ភាគរយ និងកម្មករនិយោជិតចំនួន ៥៩.១៩២ នាក់ ស្មើនឹង ៥,៥០ ភាគរយ។

*ក្រាហ្វិកទី៤. ការងារចុះបញ្ជិកាក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៦*




ផ្អែកតាមក្រាហ្វិចនេះ សហគ្រាសមានការកើនឡើងចំនួន ១៨០ សហគ្រាស ស្មើនឹង ២៣,៨៤ ភាគរយ និងកម្មករនិយោជិតចំនួន ៣.៧០១ នាក់ ស្មើនឹង ៦,៦៧ ភាគរយ ។

### ១.១.៥. ការងារភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ដែលបានចុះបញ្ជិកា បេឡាជាតិរបបសន្តិសុខសង្គម បានដាក់ឱ្យជាប់ភាគទាន ចំនួន ៦.៦១៨ សហគ្រាស ហើយក្នុងនោះសហគ្រាសបានបង់ភាគទាន មានចំនួន ៥.៤១៦ មានកម្មករនិយោជិត ចំនួន ១.០៤២.១៤៣នាក់ (ស្រី ៧២៣.៣១២ នាក់) គិតជាភាគរយសហគ្រាស ដែលបានបង់ភាគទានមានចំនួន ៨១,៨៣ ភាគរយ បើប្រៀបធៀបជាមួយសហគ្រាសជាប់ភាគទាន និងកម្មករនិយោជិតបានបង់ភាគទានមានចំនួន ៩១,៧១ភាគរយ បើប្រៀបធៀបជាមួយកម្មករនិយោជិតបានចុះបញ្ជិកា។

តារាងទី ៥. ចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករនិយោជិត បានបង់ភាគទាន

| ខែ | ឆ្នាំ | សហគ្រាស ជាប់ភាគទាន | សហគ្រាសបាន បង់ភាគទាន | កម្មករនិយោជិតបាន បានបង់ភាគទាន | | សហគ្រាស មិនបានបង់ ភាគទាន | កម្មករនិយោជិតបាន បានបង់ភាគទាន | |
|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | | សរុប | ស្រី |
| វិច្ឆិកា | ២០១៥ | 6,381 | 5,236 | 1,030,610 | 727,969 | 1,145 | 76,675 | 49,309 |
| ធ្នូ | | 6,407 | 5,374 | 1,041,116 | 727,312 | 1,033 | 75,167 | 50,887 |
| មករា | ២០១៦ | 6,491 | 5,188 | 1,041,019 | 720,467 | 1,303 | 83,121 | 51,261 |
| កុម្ភៈ | | 6,536 | 5,373 | 1,039,631 | 723,469 | 1,163 | 83,380 | 56,151 |
| មីនា | | 6,597 | 5,304 | 1,027,763 | 718,911 | 1,293 | 93,626 | 61,360 |
| មេសា | | 6,601 | 5,348 | 1,039,519 | 728,399 | 1,253 | 88,263 | 59,231 |
| ឧសភា | | 6,627 | 5,551 | 1,068,448 | 747,354 | 1,076 | 79,654 | 54,349 |
| មិថុនា | | 6,664 | 5,502 | 1,058,858 | 734,418 | 1,162 | 101,074 | 69,446 |
| កក្កដា | | 6,732 | 5,537 | 1,075,197 | 748,031 | 1,195 | 89,738 | 59,921 |
| សីហា | | 6,791 | 5,504 | 1,063,172 | 727,303 | 1,287 | 68,143 | 68,143 |
| កញ្ញា | | 6,797 | 5,499 | 978,141 | 658,306 | 1,298 | 170,266 | 130,256 |
| តុលា | | 6,786 | 5,572 | 1,042,237 | 717,808 | 1,214 | 112,001 | 79,229 |
| សរុប (ជាមធ្យមភាគ) | | 6,618 | 5,416 | 1,042,143 | 723,312 | 1,202 | 93,426 | 65,795 |

តារាងទី ៥.១៖ ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត បានបង់ភាគទាន

សហគ្រាស គ្រឹះស្ថាន សរុប បានបង់ភាគទាន និងមិនបានបង់ភាគទាន

| បរិយាយ | សហគ្រាស ជាប់ភាគទាន (មធ្យមភាគ) | សហគ្រាស បានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | សហគ្រាស មិនបានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | សរុប | ស្រី |
| ឆ្នាំ2016 | 6,618 | 5,416 | 1,042,143 | 723,312 | 1,202 | 93,426 | 65,795 |
| ឆ្នាំ2015 | 6,140 | 5,622 | 1,038,151 | 726,705 | 518 | 28,226 | 19,757 |
| បម្រែបម្រួល (± %) | +7.79% | -3.66% | +0.38% | -0.47% | +132.05% | +230.99% | +233.02% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016

## ១.១.៦. បច្ចុប្បន្នភាពការទទួលភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ទាំងអស់ដែលបានចុះបញ្ជិកា បេឡាជាតិរបបសន្តិសុខសង្គម បានធ្វើបច្ចុប្បន្នភាពភាគទានសហគ្រាស ឆ្នាំ២០១៦ ក្នុងនោះដាក់ឱ្យជាប់ភាគទាន ចំនួន ៦.៤៩០ សហគ្រាស បានបង់ភាគទាន ចំនួន ៥.៩៩៤ មានកម្មករនិយោជិត ចំនួន ១.០៩២.០០៣ នាក់ (ស្រី ៧៥៧.៦១៦ នាក់)។

តារាងទី ៦. បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត សរុប បានបង់ភាគទាន និងមិនបានបង់ភាគទាន

សហគ្រាស គ្រឹះស្ថាន សរុប បានបង់ភាគទាន និងមិនបានបង់ភាគទាន

| បរិយាយ | សហគ្រាស ជាប់ភាគទាន (មធ្យមភាគ) | សហគ្រាស បានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | សហគ្រាស មិនបានបង់ភាគ ទាន | មានកម្មករនិយោជិត (មធ្យមភាគ) | |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | សរុប | ស្រី |
| ឆ្នាំ ២០១៦ | 6,490 | 5,994 | 1,092,003 | 757,616 | 496 | 34,622 | 23,495 |
| ឆ្នាំ ២០១៥ | 6,014 | 5,801 | 1,045,367 | 742,461 | 213 | 11,862 | 6,921 |
| បម្រែបម្រួល (± %) | +7.91% | +3.33% | +4.46% | +2.04% | +132.86% | +191.87% | +239.47% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៦

តារាងទី ៦.១. បច្ចុប្បន្នភាព ភាគទាន

| បច្ចុប្បន្នភាពភាគទាន | | |
|---|---|---|
| ឆ្នាំ ២០១៦ (លានរៀល) | ឆ្នាំ ២០១៥ (លានរៀល) | បម្រែបម្រួល (± %) |
| 82,696.22 | 71,238.06 | +16.08% |

## ១.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម មានមុខងារក្នុងការធានាឱ្យមានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ ផ្នែកនេះផ្តោតជាសំខាន់លើការងារមួយចំនួនមានជាអាទិ៍ ការចុះពន្យល់ណែនាំម្ចាស់សហគ្រាស គ្រឹះស្ថាន ស្តីពីការអនុវត្តគោលនយោបាយអនុវត្តរបបសន្តិសុខសង្គម ដើម្បីឱ្យមានការចុះបញ្ជិកា និងបង់ភាគទាន នៅ ប.ស.ស, ការចុះអង្កេតគ្រោះថ្នាក់ការងារ, ការអង្កេតអំពីស្ថានភាពរបស់អ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះ, ការពង្រឹងការអនុវត្តច្បាប់តាមរយៈការធ្វើអធិការកិច្ច, ការដាក់កំហិត, ការពិន័យ និងការដាក់បណ្តឹងទៅតុលាការក្នុងករណីសហគ្រាស គ្រឹះស្ថានមិនព្រមអនុវត្តតាមច្បាប់។

លទ្ធផលចុះអធិការកិច្ច ឆ្នាំ២០១៦ សរុបចំនួន ៤.២២៣ លើក ស្មើនឹង ៦.៨៥៩ សហគ្រាស ក្នុងនោះបានដាក់ពិន័យចំនួន ១២សហគ្រាស។

### ១.២.១. ការងារអធិការកិច្ច

#### ១.២.១.១. ការចុះអធិការកិច្ចចុះបញ្ជិកា

**តារាងទី៧. ការចុះអធិការកិច្ចចុះបញ្ជិកា**

| អធិការកិច្ចចុះ បញ្ជិកា | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ឆ្នាំ2016 | | | | | | ឆ្នាំ2015 | | | | | | បម្រែបម្រួល(± %) | |
| | | លើក (ដង) | | | សហគ្រាស | | | ចំនួនលើក (ដង) | | | ចំនួនសហគ្រាស | | | | |
| | | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(1)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(2)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(3)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(4)** | លើក (1-3)/3*100 | សហគ្រាស (2-4)/4*100 |
| 1 | ចុះស្រាវជ្រាវសហគ្រាស គ្រឹះស្ថានថ្មី | 130 | 326 | **456** | 383 | 662 | **1,045** | 312 | 635 | **947** | 368 | 687 | **1,055** | -52% | -0.95% |
| 2 | ចុះចែកលិខិតជូនដំណឹងអធិការកិច្ច | 80 | 173 | **253** | 171 | 365 | **536** | 482 | 520 | **1,002** | 525 | 520 | **1,045** | -75% | -48.71% |
| 3 | ចុះអធិការកិច្ចចុះបញ្ជិកា | 70 | 187 | **257** | 157 | 416 | **573** | 124 | 520 | **644** | 168 | 520 | **688** | -60% | -16.72% |
| 4 | បានដាក់លិខិតដាក់កំហិត | 64 | 121 | **185** | 64 | 121 | **185** | 150 | 112 | **262** | 150 | 112 | **262** | -29% | -29.39% |
| 5 | ចុះអធិការកិច្ចផាកពិន័យ | 21 | 1 | **22** | 21 | 1 | **22** | 26 | - | **26** | 26 | - | **26** | -15% | -15.38% |
| 6 | សម្របសម្រួលចុះបញ្ជិកា | 51 | 236 | **287** | 51 | 236 | **287** | 122 | 186 | **308** | 122 | 186 | **308** | -7% | -6.82% |
| សរុបលទ្ធផលនៃការចុះអធិការកិច្ច | | 416 | 1,044 | **1,460** | 847 | 1,801 | **2,648** | 1,216 | 1,973 | **3,189** | 1,359 | 2,025 | **3,384** | -54% | -22% |

#### ១.២.១.២. ការចុះអធិការកិច្ចការងារតែមួយ

មន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចសាមញ្ញទី២ ជាមួយក្រុមអធិការកិច្ចតែមួយបានចំនួន ១.៣៨១ លើក ស្មើនឹង ១.៣៨១ សហគ្រាស ក្នុងនោះបានរកឃើញសហគ្រាសចំនួន ០៩ រាយការណ៍ចំនួនកម្មករនិយោជិតមិនត្រឹមត្រូវ, សហគ្រាស ចំនួន ០១ ប្រកាសប្រាក់ឈ្នួលមិនត្រឹមត្រូវ, សហគ្រាសចំនួន ០១ បង់ភាគទានមក ប.ស.ស មិនត្រឹមត្រូវ និងសហគ្រាសចំនួន ១០ ជំទាស់នឹងការអនុវត្តមុខងារអធិការ ប.ស.ស។ ចាប់តាំងពីពាក់កណ្តាល ឆ្នាំ២០១៦ សម្រាប់នៅរាជធានីភ្នំពេញ មន្ត្រីអធិការរបបសន្តិសុខសង្គម បានផ្អាកសកម្មភាពចុះចម្រុះជាបណ្តោះអាសន្នមួយរយៈសិន ដោយមន្ត្រីអធិការត្រូវចុះទៅសម្របសម្រួល (បើកផ្លូវ) នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តមួយចំនួន។ ដោយឡែក សម្រាប់មន្ត្រីអធិការនៅតាមការិយាល័យ ប.ស.ស សាខាខេត្ត នៅបន្តចុះចម្រុះជាមួយមន្ត្រីរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាធម្មតា។

## ១.២.១.៣. ការចុះអធិការកិច្ចទារភាគទាន

*តារាងទី ៨. ការងារចុះអធិការកិច្ចភាគទាន*

| ល.រ | សកម្មភាព | ឆ្នាំ2016 | | | | | | ឆ្នាំ2015 | | | | | | បម្រែបម្រួល(± %) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លើក (ដង) | | | សហគ្រាស | | | លើក (ដង) | | | សហគ្រាស | | | | |
| | | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(1)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(2)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(3)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប(4)** | លើក (1-3)/3*100 | សហគ្រាស (2-4)/4*100 |
| ១ | ចុះអធិការកិច្ចបង់ភាគទាន | 159 | 57 | **216** | 159 | 132 | **291** | 112 | 23 | **135** | 122 | 33 | **155** | +60% | +88% |
| ២ | បានដាក់លិខិតដាក់កំហិត | 48 | 60 | **108** | 48 | 122 | **170** | 46 | 18 | **64** | 52 | 30 | **82** | +69% | +107% |
| ៣ | សម្របសម្រួលបង់ភាគទាន | 60 | 42 | **102** | 60 | 87 | **147** | 14 | 9 | **23** | 22 | 14 | **36** | +343% | +308% |
| ៤ | ចុះអធិការកិច្ចពិន័យរាប់កម្មករ | 15 | 37 | **52** | 15 | 37 | **52** | 12 | 0 | **12** | 18 | 0 | **18** | +333% | +189% |
| ៥ | ពិន័យចេញដោយនាយក ប.ស.ស | 8 | 12 | **20** | 8 | 12 | **20** | 6 | 9 | **15** | 6 | 9 | **15** | +33% | +33% |
| ៦ | អធិការកិច្ចទារប្រាក់ពិន័យ | 6 | 9 | **15** | 6 | 9 | **15** | 5 | 0 | **5** | 5 | 0 | **5** | +200% | +200% |
| សរុបការងារចុះអធិការកិច្ចភាគទាន | | 296 | 217 | **513** | 296 | 399 | **695** | 195 | 59 | **254** | 225 | 86 | **311** | +102% | +123% |

## ១.២.១.៤. ការងារផ្សេងៗផ្នែកអធិការកិច្ច

*តារាងទី ៩.ការងារផ្សេង ៗផ្នែកអធិការកិច្ច*

| ល.រ | សកម្មភាព | ឆ្នាំ2016 | | | | | | ឆ្នាំ2015 | | | | | | បម្រែបម្រួល(± %) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លើក (ដង) | | | សហគ្រាស | | | លើក (ដង) | | | សហគ្រាស | | | | |
| | | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប (1)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប (2)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប (3)** | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | **សរុប (4)** | លើក (1-3)/3*100 | សហគ្រាស (2-4)/4*100 |
| 1 | ចុះពិនិត្យសហគ្រាស គ្រឹះស្ថានសង្ស័យបិទ-បើកឬព្យួរ | 27 | 20 | **47** | 54 | 41 | **95** | 37 | 67 | **104** | 86 | 144 | **230** | -54.81% | -58.70% |
| 2 | ចុះចែកវិញ្ញាបនបត្រសហគ្រាស គ្រឹះស្ថាន | 15 | 6 | **21** | 23 | 21 | **44** | 12 | - | **12** | 22 | - | **22** | +75.00% | +100.00% |
| 3 | ចុះពន្យល់ពីអត្ថប្រយោជន៍ ប.ស.ស | 9 | 6 | **15** | 19 | 10 | **29** | 14 | - | **14** | 32 | - | **32** | +7.14% | -9.38% |
| 4 | ចុះសម្របសម្រួលបង់ភាគទាន | - | - | **-** | - | - | **-** | 8 | - | **8** | 16 | - | **16** | -100.00% | -100.00% |
| 5 | ចុះចែកលិខិតទារភាគទាន និងប្រាក់ពិន័យ ព្រមទាំងការប្រាក់ | 215 | | **215** | 477 | | **477** | 24 | - | **24** | 824 | - | **824** | +795.83% | -42.11% |
| 6 | ចុះអធិការកិច្ចសង្ស័យលាក់កម្មករ | 5 | 4 | **9** | 12 | 11 | **23** | | - | **-** | | - | **-** | #DIV/0! | #DIV/0! |
| 7 | អង្កេតរបាយការណ៍ហានិភ័យការងារ | 16 | 12 | **28** | 215 | 123 | **338** | | - | **-** | | - | **-** | #DIV/0! | #DIV/0! |
| 8 | ចុះពិនិត្យមើលសហគ្រាសសុំផ្អាកបង់ភាគទាន | 9 | 10 | **19** | 17 | 11 | **28** | 11 | - | **11** | 24 | - | **24** | +72.73% | +16.67% |
| 9 | ចុះចែកលិខិតប្រជុំផ្សព្វផ្សាយរបស់ការិ.គោលនយោបាយ | 234 | | **234** | 542 | | **542** | | - | **-** | | - | **-** | #DIV/0! | #DIV/0! |
| 10 | ចុះសម្របសម្រួលការងារនិងពន្យល់នីតិវិធីការងារដល់មន្ត្រី-បុគ្គលិក សាខាប.ស.ស ខេត្ត | 8 | - | **8** | 12 | | **12** | 7 | - | **7** | 12 | - | **12** | +14.29% | 0.00% |
| សរុបអធិការកិច្ចផ្សេងៗ | | 538 | 58 | **596** | 1,371 | 217 | **1,588** | 113 | 67 | **180** | 1,016 | 144 | **1,160** | +231.11% | +36.90% |

ការងារចុះសម្របសម្រួល និងពន្យល់សហគ្រាស គ្រឹះស្ថាន (ចុះបើកផ្លូវ) ដើម្បីកំណត់អត្តសញ្ញាណកម្មករនិយោជិតសម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមសាខា ប.ស.ស ខេត្ត-ខណ្ឌ មានដូចជា រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តស្វាយរៀង, ខេត្តកំពង់ស្ពឺ, ខេត្តកំពង់ឆ្នាំង, ខេត្តព្រះសីហនុ, ខេត្តកំពង់ចាម, ខេត្តព្រៃវែង សរុបចំនួន ២៧៣លើក ស្មើនឹង ៥៤៧សហគ្រាស។

## ១.២.១.៥. ការងារអង្កេតហានិភ័យការងារ

### ១.២.១.៥.១. របាយការណ៍ហានិភ័យការងារ និងលទ្ធផលអង្កេត

**តារាងទី ១០. របាយការណ៍ហានិភ័យការងារ និងលទ្ធផលអង្កេត**

| សកម្មភាព | | ឆ្នាំ2016 | | | ឆ្នាំ2015 | | | បម្រែបម្រួល(± %) |
|---|---|---|---|---|---|---|---|---|
| | | ថ្នាក់កណ្តាល | ថ្នាក់ខេត្ត | **សរុប (1)** | ថ្នាក់កណ្តាល | ថ្នាក់ខេត្ត | **សរុប (2)** | (1-2)/2*100 |
| របាយការណ៍ហានិភ័យការងារ | | 15,497 | 21,237 | **36,734** | 14,637 | 16,282 | **30,919** | +18.81% |
| លទ្ធផលអង្កេត | ថ្មី | 9,178 | 11,797 | **20,975** | 8,943 | 11,305 | **20,248** | +3.59% |
| | ចាស់ | 5,612 | 8,570 | **14,182** | 5,833 | 4,991 | **10,824** | +31.02% |
| | សរុប | 14,790 | 20,367 | **35,157** | 14,776 | 16,296 | **31,072** | +13.15% |

ប្រភព៖ បេឡាជាតិ របបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យក្នុងឧបសម្ព័ន្ធទី ៧)

#### ១.២.១.៥.២. ស្ថានភាពហានិភ័យការងារ

បានទទួលរបាយការណ៍ហានិភ័យការងារចំនួន ៣៦.៧៣៤ នាក់ ក្នុងនោះ អង្កេតបាន ចំនួន ៣៥.១៥៧ នាក់ មានហានិភ័យការងារសរុបចំនួន ៣៤.៥១៣នាក់ រួមមានគ្រោះថ្នាក់នៅកន្លែងធ្វើការមានចំនួន ២៤.៩០២នាក់ និងគ្រោះថ្នាក់នៅពេលធ្វើដំណើរមានចំនួន ៩.៦០៨នាក់ និង ជំងឺវិជ្ជាជីវៈ ចំនួន ០៣នាក់ (ជំងឺវិជ្ជាជីវៈ ០៣នាក់ ត្រូវបានរាប់បញ្ចូលក្នុងគ្រោះថ្នាក់កន្លែងធ្វើការងារ) និង មិនមែនហានិភ័យការងារមានចំនួន ៦៤៤ នាក់ *(ព័ត៌មាននេះដូចក្នុងតារាងទី១២)*។

#### ១.២.១.៥.៣. អង្កេតសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី

តារាងទី ១១. អង្កេត សិទ្ធិទទួលបានតាវកាលិកឧត្តរជីវី

| អង្កេត សិទ្ធិទទួលបានតាវកាលិកឧត្តរជីវី | | | |
|---|---|---|---|
| សកម្មភាព | តាវកាលិកឧត្តរជីវី (ឯកសារ) | | |
| | អង្កេត | បានផ្តល់ | មិនបានផ្តល់ |
| ឆ្នាំ2016 | 170 | 100 | 70 |
| ឆ្នាំ2015 | 186 | 106 | 80 |
| បម្រែបម្រួល(± %) | -8.60% | -5.66% | -12.50% |

#### ១.២.១.៦. ការងារនីតិកម្ម

បានចុះធ្វើការផាកពិន័យការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន ចំនួន ០៧ សហ-គ្រាស និងបន្តតាមដាននីតិវិធីតាមផ្លូវច្បាប់ចំពោះសហគ្រាស គ្រឹះស្ថាន ចំនួន ០៤ ដែលបានប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ និងបានពិន័យសហគ្រាស គ្រឹះស្ថាន ចំនួន១២ ដែលមានកំហុសទាក់ទងនឹងការរាយការណ៍ចំនួនកម្មករនិយោជិតមក ប.ស.ស មិនត្រឹមត្រូវ, ការប្រកាសប្រាក់ឈ្នួលមិនត្រឹមត្រូវ, ការមិនបង់ភាគទាន, ការជំទាស់នឹងការអនុវត្តមុខងារអធិការ ប.ស.ស ព្រមទាំងពិន័យផ្សេងៗទៀតជាដើម។

### ១.៣. ការផ្តល់សេវាតាវកាលិក

ថ្វីត្បិតចំនួនគ្រោះថ្នាក់ការងារបានបន្តកើតមានជាបន្តបន្ទាប់ក្តីក៏ដោយ ប.ស.ស បានរៀបចំ អភិវឌ្ឍន៍បែបបទការងារ និងបានពង្រីកយន្តការនៃការផ្តល់តាវកាលិកឱ្យកាន់តែមានភាពងាយស្រួលទូលំ-ទូលាយបន្ថែមទៀត ដើម្បីឱ្យកម្មករនិយោជិត ដែលទទួលរងនូវគ្រោះថ្នាក់ការងារ ទទួលបានសេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ តាមរយៈនេះ ប.ស.ស បានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យទាមទារតាវកាលិកហានិភ័យការងារ ដែលប្រព័ន្ធនេះអាចគ្រប់គ្រងបាននូវរបាយការណ៍ហានិភ័យការងារ ការអង្កេត និងការគណនាតាវកាលិក ដែលវាបានពន្លឿនក្នុងការផ្តល់តាវកាលិក និងមានភាពត្រឹមត្រូវ។ ប.ស.ស ក៏បានពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនបានចំនួន ៩៧ និងបានដាក់ភ្នាក់ងារឱ្យប្រចាំការនៅតាមមន្ទីរពេទ្យបានមួយចំនួន សម្រាប់ជួយសម្របសម្រួលដល់ជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ឱ្យទទួលបានការសម្រាកព្យាបាល និងងាយស្រួលទទួលបានសេវានៅកន្លែងដែលជិត។ មួយវិញទៀតក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប.ស.ស បានបញ្ជូនមន្ត្រីទៅដល់កន្លែងគ្រោះថ្នាក់ផ្ទាល់ ដើម្បីជួយសម្របសម្រួល និងធ្វើអន្តរាគមន៍បានទាន់ពេលវេលា។

## ១.៣.១. របាយការណ៍ហានិភ័យការងារ

សម្រាប់ឆ្នាំ២០១៦ នេះ ប.ស.ស បានទទួលរបាយការណ៍ហានិភ័យការងារពីបណ្ដាសហគ្រាស គ្រឹះស្ថាន តាមបណ្ដារាជធានី-ខេត្ត នៅទូទាំងប្រទេសមានចំនួន ៣៣.១១៦ ករណី មានកម្មករ-និយោជិតចំនួន ៣៦.៧៣៤ នាក់ ស្រីចំនួន ២៧.៣៣៨ នាក់ ហើយតាមរយៈលទ្ធផលនៃការអង្កេតហានិ-ភ័យការងារមានចំនួន ៣៤.៥១៣នាក់ ស្រីចំនួន ២៥.៦៨៣នាក់ ក្នុងនោះគ្រោះថ្នាក់កន្លែងធ្វើការមានចំនួន ២៤.៩០២ នាក់ ស្រី ១៩.៤៧៧ នាក់ គ្រោះថ្នាក់ពេលធ្វើដំណើរមានចំនួន ៩.៦០៨នាក់ ស្រី ៦.២០៤ នាក់ និងជំងឺវិជ្ជាជីវៈ មានចំនួន ០៣នាក់ ស្រី ០២នាក់។ ចំពោះកម្រិតនៃរបួសវិញមានរបួសស្រាល ចំនួន ៣១.៨៩៩នាក់ ស្រី ២៤.១៦២នាក់ របួសធ្ងន់ចំនួន ២.៤៤៦នាក់ ស្រី ១.៤៦១នាក់ ស្លាប់ ចំនួន ១៦៨ នាក់ ស្រី ៦០នាក់ និងមិនមែនជាហានិភ័យការងារចំនួន ៦៤៤នាក់ ស្រី ៤៨៨នាក់។

**តារាងទី ១២៖ ស្ថានភាពហានិភ័យការងារ**

| បរិយាយ | ស្ថានភាពរបាយការណ៍ហានិភ័យការងារ | | | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | | មិនមែនហានិភ័យការងារ (នាក់) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទទួលរបាយការណ៍ហានិភ័យការងារ (នាក់) | សមាជិកសរុប | បម្រែបម្រួល (± %) | សរុប | | ស្រាល | | ធ្ងន់ | | ស្លាប់ | | | |
| | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 36,734 | 1,136,271 | 3.23% | 34,513 | 25,683 | 31,899 | 24,162 | 2,446 | 1,461 | 168 | 60 | 644 | 488 |
| ឆ្នាំ2015 | 30,919 | 1,077,079 | 2.87% | 30,281 | 22,273 | 27,804 | 20,802 | 2,296 | 1,404 | 181 | 67 | 791 | 624 |
| បម្រែបម្រួល (± %) | +12.62% | | | +13.98% | +15.31% | +14.73% | +16.15% | +6.53% | +4.06% | -7.18% | -10.45% | -18.58% | -21.79% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៨)

**តារាងទី ១២.១៖ ស្ថានភាពហានិភ័យការងារ ថ្នាក់កណ្ដាល**

| បរិយាយ | ស្ថានភាពរបាយការណ៍ហានិភ័យការងារ | | | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | | មិនមែនហានិភ័យការងារ (នាក់) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទទួលរបាយការណ៍ហានិភ័យការងារ (នាក់) | សមាជិកសរុប | បម្រែបម្រួល (± %) | សរុប | | ស្រាល | | ធ្ងន់ | | ស្លាប់ | | | |
| | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 18,829 | 646,506 | 2.91% | 17,807 | 12,864 | 16,475 | 12,087 | 1,277 | 757 | 55 | 20 | 326 | 227 |
| ឆ្នាំ2015 | 16,058 | 621,537 | 2.58% | 15,658 | 10,967 | 14,410 | 10,254 | 1,190 | 695 | 58 | 18 | 488 | 376 |
| បម្រែបម្រួល (± %) | +12.73% | | | +13.72% | +17.30% | +14.33% | +17.88% | +7.31% | +8.92% | -5.17% | +11.11% | -33.20% | -39.63% |

**តារាងទី ១២.២៖ ស្ថានភាពហានិភ័យការងារ ថ្នាក់ខេត្ត**

| បរិយាយ | ស្ថានភាពរបាយការណ៍ហានិភ័យការងារ | | | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | | មិនមែនហានិភ័យការងារ (នាក់) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទទួលរបាយការណ៍ហានិភ័យការងារ (នាក់) | សមាជិកសរុប | បម្រែបម្រួល (± %) | សរុប | | ស្រាល | | ធ្ងន់ | | ស្លាប់ | | | |
| | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 17,905 | 489,765 | 3.66% | 16,706 | 12,819 | 15,424 | 12,075 | 1,169 | 704 | 113 | 40 | 318 | 261 |
| ឆ្នាំ2015 | 14,861 | 455,542 | 3.26% | 14,623 | 11,306 | 13,394 | 10,548 | 1,106 | 709 | 123 | 49 | 303 | 248 |
| បម្រែបម្រួល (± %) | +12.06% | | | +14.24% | +13.38% | +15.16% | +14.48% | +5.70% | -0.71% | -8.13% | -18.37% | +4.95% | +5.24% |

**តារាងទី ១៣៖ លទ្ធផលអង្កេតហានិភ័យការងារ**

| បរិយាយ | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សរុប | | គ្រោះថ្នាក់កន្លែងធ្វើការ | | គ្រោះថ្នាក់ពេលធ្វើដំណើរ | | ជំងឺវិជ្ជាជីវៈ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 34,513 | 25,683 | 24,902 | 19,477 | 9,608 | 6,204 | 3 | 2 |
| ឆ្នាំ2015 | 30,281 | 22,273 | 22,487 | 17,280 | 7,791 | 4,991 | 3 | 2 |
| បម្រែបម្រួល (± %) | +13.98% | +15.31% | +10.74% | +12.71% | +23.32% | +24.30% | +0.00% | +0.00% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016 (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៨)

| តារាងទី ១៣.១៖ លទ្ធផលអង្កេតហានិភ័យការងារ ថ្នាក់កណ្តាល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
| | សរុប | | គ្រោះថ្នាក់កន្លែងធ្វើការ | | គ្រោះថ្នាក់ពេលធ្វើដំណើរ | | ជំងឺវិជ្ជាជីវៈ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 17,808 | 12,865 | 12,915 | 9,875 | 4,892 | 2,989 | 1 | 1 |
| ឆ្នាំ2015 | 15,658 | 10,967 | 11,652 | 8,643 | 4,003 | 2,322 | 3 | 2 |
| បម្រែបម្រួល (± %) | +13.73% | +17.31% | +10.84% | +14.25% | +22.21% | +28.73% | -66.67% | -50.00% |

| តារាងទី ១៣.២៖ លទ្ធផលអង្កេតហានិភ័យការងារ ថ្នាក់ខេត្ត | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
| | សរុប | | គ្រោះថ្នាក់កន្លែងធ្វើការ | | គ្រោះថ្នាក់ពេលធ្វើដំណើរ | | ជំងឺវិជ្ជាជីវៈ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 16,705 | 12,818 | 11,987 | 9,602 | 4,716 | 3,215 | 2 | 1 |
| ឆ្នាំ2015 | 14,623 | 11,306 | 10,835 | 8,637 | 3,788 | 2,669 | - | - |
| បម្រែបម្រួល (± %) | +14.24% | +13.37% | +10.63% | +11.17% | +24.50% | +20.46% | #DIV/0! | #DIV/0! |

## ១.៣.២. ប្រៀបធៀបស្ថានភាពហានិភ័យការងារ ឆ្នាំ២០១៦ និងឆ្នាំ២០១៥

*ក្រាហ្វិកទី៥. ចំនួនកម្មករនិយោជិតបានចុះបញ្ជិកា និងចំនួនហានិភ័យការងារ (នាក់)*




តាមក្រាហ្វិកខាងលើបានបង្ហាញឱ្យឃើញថា ហានិភ័យការងារ ឆ្នាំ២០១៦ មានកម្មករនិយោជិត ចំនួន ៣៤.៥១៣នាក់ រីឯនៅឆ្នាំ២០១៥ ចំនួន ៣០.២៨១នាក់ ដូច្នេះចំនួននេះមានការកើនឡើង ៤.២៣២នាក់ ស្មើនឹង ១៣,៩៨ ភាគរយ។ ចំពោះកម្មករនិយោជិតបានចុះបញ្ជិកាវិញមានការកើនឡើង ចំនួន ៥៩.១៩២ នាក់ ស្មើនឹង ៥,៥០ ភាគរយ។ យើងឃើញថាចំនួនហានិភ័យការងារមានការកើនឡើង ចំនួន ១៣,៩៨ ភាគរយ រីឯចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកាមានការកើនឡើងចំនួន ៥,៥០ ភាគរយ ដូច្នេះបើប្រៀបធៀបជាមួយនឹងកំណើនទាំងពីរ ចំនួនហានិភ័យការងារមានការកើនឡើងស្របនឹង ចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។ ចំពោះអត្រាហានិភ័យការងារកម្មករនិយោជិត ធៀបជាមួយ កម្មករនិយោជិត បានចុះបញ្ជិកានៅឆ្នាំ២០១៦ មានចំនួន ៣,០៤% និងនៅឆ្នាំ២០១៥ មានចំនួន ២,៨១%។

*ក្រាហ្វិកទី៦. ស្ថានភាពហានិភ័យការងារតាមប្រភេទ និងកម្រិតរបួស(នាក់)*







ស្ថានភាពហានិភ័យការងារនៅឆ្នាំ២០១៦ មានការកើនឡើងចំពោះគ្រោះថ្នាក់នៅកន្លែងធ្វើការចំនួន ២.៤១៥នាក់ ស្មើនឹង ១០,៧៤ភាគរយ, កម្រិតរបួសស្រាលកើនឡើងចំនួន ៤.០៩៥ នាក់ ស្មើនឹង ១៤,៧២ភាគរយ, របួសធ្ងន់កើនឡើងចំនួន ១៥០នាក់ ស្មើនឹង ៦,៥៣ ភាគរយ និងស្លាប់ថយចុះចំនួន -១៣នាក់ ស្មើនឹង -៧,១៨ភាគរយ។ ចំពោះស្ថានភាពហានិភ័យការងារនៅពេលធ្វើដំណើរមានការកើនឡើងចំនួន ១.៨១៧នាក់ ស្មើនឹង ២៣,៣២ភាគរយ និងជំងឺវិជ្ជាជីវៈមានការស្មើគ្នាបើធៀបនឹងឆ្នាំ២០១៥។ ការកើនឡើងនូវករណីហានិភ័យការងារ នេះវាស្របនឹងការកើនឡើងនៃចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។ *(ទិន្នន័យអំពីចំណាត់ថ្នាក់ហានិភ័យការងារសូមមើលក្នុងឧបសម្ព័ន្ធទី១០)*

### ១.៣.៣. ការទាមទារតាវកាលិកហានិភ័យការងារ

តាមរយៈនៃការទាមទារតាវកាលិក ប.ស.ស ឆ្នាំ២០១៦ ផ្អែកតាមតារាងទី១៤ បានទទួលការទាមទារតាវកាលិកហានិភ័យការងារសរុបចំនួន ១៨.៩៣២នាក់ ស្រី ១៣.២៥៥ នាក់ ស្មើនឹង ៣១.៩៧៤ ឯកសារ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ការទាមទារតាវកាលិកមានតែចំនួន ២៥.៨៥៩ ឯក-សារ ដូច្នេះចំនួននេះមានការកើនឡើង ៦.១១៥ ឯកសារ ស្មើនឹង ២៣,៦៥ ភាគរយ។

***តារាងទី ១៤. ការទាមទារតាវកាលិកហានិភ័យការងារ***

| ការទាមទារតាវកាលិកហានិភ័យការងារ | | | | | |
|---|---|---|---|---|---|
| ល.រ | ប្រភេទតាវកាលិក | ការទាមទារ (ឯកសារ) | | | |
| | | ឆ្នាំ2016 | ឆ្នាំ2015 | បម្រែបម្រួល(± %) | |
| ១ | តាវកាលិកថែទាំ និង ព្យាបាល | **15,448** | 12,804 | +20.65% |
| ២ | តាវកាលិកបាត់បង់សមត្ថភាពបណ្ដោះអាសន្ន | **15,968** | 12,589 | +26.84% |
| ៣ | តាវកាលិកបាត់បង់. អចិន្ត្រៃយ៍ក្រោម ២០% (វិភាជន៍) | **92** | 68 | +35.29% |
| ៤ | តាវកាលិកបាត់បង់. អចិន្ត្រៃយ៍ចាប់ពី ២០% (ធនលាភ) | **145** | 118 | +22.88% |
| ៥ | តាវកាលិកឧត្តរជីវី | **118** | 85 | +38.82% |
| ៦ | វិភាជន៍បូជាសព | **174** | 179 | -2.79% |
| ៧ | តាវកាលិកអ្នកចាំថែរក្សា | **10** | 6 | +66.67% |
| ៨ | សេវាបុននីតិសម្បទា | **19** | 10 | +90.00% |
| សរុប | | **31,974** | 25,859 | +23.65% |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016**

## ១.៣.៤. ការចំណាយតាមប្រភេទតាវកាលិក

ឆ្នាំ២០១៦ ផ្អែកតាមតារាងទី ១៥ ប.ស.ស បានផ្តល់តាវកាលិកហានិភ័យការងារបាន ចំនួន ៣៦.៥០៨ ឯកសារ កើនឡើងចំនួន ៨.០៣៦ ឯកសារ ស្មើនឹង ២៨,២២ ភាគរយ ដែលមាន ចំនួនជនរងគ្រោះ ១៩.២៦២ នាក់ ស្រី ១៣.៥៥៦នាក់ កើនឡើងចំនួន ៣.៧១១ នាក់ ស្មើនឹង ២៣,៨៦ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០១៥។

*តារាងទី ១៥. ការផ្តល់តាវកាលិកហានិភ័យការងារ*

| ការផ្តល់តាវកាលិកហានិភ័យការងារ | | | | |
|---|---|---|---|---|
| ល.រ | ប្រភេទតាវកាលិក | ការផ្តល់តាវកាលិក (ឯកសារ) | | |
| | | ឆ្នាំ2016 | ឆ្នាំ2015 | បម្រែបម្រួល(± %) |
| ១ | តាវកាលិកព្យាបាល | **13,881** | 11,402 | +21.74% |
| ២ | តាវកាលិកថែទាំ | **4,164** | 3,176 | +31.11% |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | **16,238** | 12,388 | +31.08% |
| ៤ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្រោម ២០ % (វិភាជន៍) | **92** | 67 | +37.31% |
| ៥ | តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍លើ ២០ % (ធនលាភ) | **668** | 451 | +48.12% |
| ៦ | វិភាជន៍បូជាសព | **175** | 180 | -2.78% |
| ៧ | តាវកាលិកឧត្តរជីវី | **1,226** | 772 | +58.81% |
| ៨ | តាវកាលិកអ្នកចាំថែរក្សា | **45** | 26 | +73.08% |
| ៩ | សេវាបុននីតិសម្បទា | **19** | 10 | +90.00% |
| សរុប | | **36,508** | 28,472 | +28.22% |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2016**

តាមរយៈការទាមទារតាវកាលិកពីជនរងគ្រោះ ប.ស.ស បានចេញសេចក្តីសម្រេចផ្តល់តាវ-កាលិកហានិភ័យការងារ ដល់កម្មករនិយោជិតដែលរងគ្រោះក្នុងឆ្នាំ២០១៦ ផ្អែកតាមតារាងទី១៦ ចំនួន *១៩.២៦២* នាក់ ស្មើនឹង *៣៦.៥០៨*ឯកសារ សម្រាប់ការព្យាបាលនៅតាមមន្ទីរពេទ្យ និងការថែទាំ, ការបាត់-បង់សមត្ថភាពការងារបណ្តោះអាសន្ន, ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, ឧត្តរជីវី, វិភាជន៍បូជាសព តាវកាលិកអ្នកចាំថែរក្សាសរុបចំនួន *៧,៨៦៨.៣៧* លានរៀល និងចេញសេចក្តីសម្រេចទូទាត់ថ្លៃព្យាបាលវេជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការចំនួន *៦៦* មានកម្មករនិយោជិតព្យាបាលចំនួន ២២.៤១៩នាក់ ចំណាយទឹកប្រាក់ ចំនួន *៦,៤២៣.៤៤* លានរៀល និងមន្ទីរពេទ្យក្រៅផ្លូវការ ចំនួន *៤៧* មានកម្មករនិយោជិតព្យាបាលចំនួន *១៧.២៣៩* នាក់ ចំណាយទឹកប្រាក់ចំនួន *១,៤៣៧.១៤* លានរៀល និងសេវាបុននីតិសម្បទា ចំនួន ១៩ នាក់ ចំណាយទឹកប្រាក់ចំនួន *៨៥.១៧* លានរៀល។ ដូច្នេះសរុបការចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ និងទូទាត់ថ្លៃព្យាបាលវេជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការ ក្រៅផ្លូវការ និងសេវាបុន-នីតិសម្បទាសម្រាប់ឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន ១៥,៨១៤.១២លានរៀល។

តារាងទី ១៦. ការចំណាយតាមប្រភេទតាវកាលិកហានិភ័យការងារ

| ល.រ | ក. ប្រភេទតាវកាលិកហានិភ័យការងារ | ឆ្នាំ2016 (លានរៀល) | ឆ្នាំ2015 (លានរៀល) | បម្រែបម្រួល (± %) |
|---|---|---|---|---|
| ១ | តាវកាលិកព្យាបាល | 2,448.68 | 2,213.45 | +10.63% |
| ២ | តាវកាលិកថែទាំ | 166.30 | 111.10 | +49.68% |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពបណ្តោះអាសន្ន | 2,551.02 | 1,806.87 | +41.18% |
| ៤ | តាវកាលិក.អចិន្ត្រៃយ៍ក្រោម ២០% *(វិភាជន៍)* | 410.83 | 177.96 | +130.86% |
| ៥ | តាវកាលិក.អចិន្ត្រៃយ៍ចាប់ពី ២០% *(ធនលាភ)* | 468.64 | 267.74 | +75.03% |
| ៦ | វិភាជន៍បូជាសព | 668.00 | 720.00 | -7.22% |
| ៧ | តាវកាលិកឧត្តរជីវី *(ធនលាភ)* | 1,110.73 | 594.25 | +86.91% |
| ៨ | តាវកាលិកអ្នកថាំថែរក្សា | 44.17 | 22.20 | +98.94% |
| ៩ | សេវាបុននីតិសម្បទា | 85.17 | 41.18 | +106.84% |
| | សរុប (ក) | 7,953.54 | 5,954.76 | +33.57% |
| ល.រ | ខ. ប្រភេទមូលដ្ឋានសុខាភិបាល | ឆ្នាំ2016 (លានរៀល) | ឆ្នាំ2015 (លានរៀល) | បម្រែបម្រួល (± %) |
| ១ | មន្ទីរពេទ្យផ្លូវការ | 6,423.44 | 5,014.70 | +28.09% |
| ២ | មន្ទីរពេទ្យក្រៅផ្លូវការ | 1,437.14 | 1,088.64 | +32.01% |
| | សរុប (ខ) | 7,860.58 | 6,103.34 | +28.79% |
| | សរុបរួម (ក+ខ) | 15,814.12 | 12,058.10 | +31.15% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៦

ចំនួនអ្នកស្នើសុំ និងចំនួនអ្នកដែលត្រូវបានផ្តល់តាវកាលិកមិនដូចគ្នាទេ ដោយសារឯកសារមួយចំនួនបានបន្សល់ទុកមកពីឆ្នាំចាស់ ហើយបន្តផ្តល់រហូតមកដល់ឆ្នាំបន្ទាប់។ ការផ្តល់តាវកាលិកសម្រាប់ឆ្នាំ២០១៦ នេះ ចំណាយថវិកាកើនចំនួន ៣,៧៥៦.០២លានរៀល ត្រូវជា ៣១,១៥ភាគរយ។ ការកើនឡើងនៃការស្នើសុំ និងការផ្តល់តាវកាលិកនេះ ដោយសារការកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារស្របគ្នានឹងការកើនឡើងកម្មករនិយោជិតដែលបានចុះបញ្ជិកា។

### ១.៣.៥. ការខារវាយតម្លៃកម្រិតបាត់បង់សមត្ថភាពអចិន្ត្រៃយ៍

គណៈកម្មការវេជ្ជសាស្រ្ត បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព, យុត្តិធម៌ មនសិការវិជ្ជាជីវៈ និងកសាងបានជំនឿទុកចិត្តពីសំណាក់មជ្ឈដ្ឋានទូទៅ និងសមាជិករបស់ ប.ស.ស ជាពិសេសពីនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថាន មកលើការអនុវត្តរបស់ ប.ស.ស តាមរយៈការចូលរួមបង់ភាគទានធានារ៉ាប់រងហានិភ័យការងារជូនកម្មករនិយោជិត ហើយវាក៏បានជំរុញឱ្យពួកគេផ្តល់ព័ត៌មានពិតពីចំនួនកម្មករនិយោជិត និងពីចំនួនប្រាក់ខែរបស់ពួកគេ ដើម្បីជៀសវាងការបាត់បង់អត្ថប្រយោជន៍ដែលមានចែងនៅក្នុងច្បាប់។

តារាងទី១៧. វាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

| វាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ | | | | | |
|---|---|---|---|---|---|
| បរិយាយ | ប្រជុំ (លើក) | កម្រិតតិចជាង ២០% | | កម្រិតធំជាង ២០% | |
| | | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2016 | 23 | 69 | 23 | 128 | 59 |
| ឆ្នាំ2015 | 13 | 31 | 16 | 46 | 15 |
| បម្រែបម្រួល(± %) | +76.92% | +122.58% | +43.75% | +178.26% | +293.33% |

ជនរងគ្រោះចំនួន ១២៨នាក់ ទទួលបានតាវកាលិកអចិន្ត្រៃយ៍ធំជាង២០% ក្នុងនោះបានផ្តល់សេវាបុននីតិសម្បទា រួមទាំងផ្តល់តាវកាលិកអ្នកថាំថែរក្សា ដល់ជនរងគ្រោះចំនួន ៨ នាក់ ស្រី ៣នាក់។

## ១.៤. ការងាររៀបចំបុននីតិសម្បទា

អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទ-ប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, អនុក្រឹត្យស្តីពីការបង្កើត ប.ស.ស និងប្រកាសស្តីពីតាវកាលិកហានិភ័យការងារ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងាររអចិន្ត្រៃយ៍មានសិទ្ធិទទួលបានសេវាបុននីតិសម្បទា (ស្តារលទ្ធភាពពលកម្ម) រួមមានការផ្តល់នូវឧបករណ៍ ឬ អវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬ គ្រូពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស ព្រមទាំងសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ។ ចំពោះការផ្តល់សេវាខាងលើ កន្លងមក ប.ស.ស ពុំទាន់បានផ្តល់ឱ្យបានពេញលេញនៅឡើយទេ ការផ្តល់សេវាមួយចំនួនភាគច្រើនជាសេវាស្តារលទ្ធភាពពល-កម្មផ្នែកវេជ្ជសាស្ត្រ ដែលរួមមានការផ្តល់ឧបករណ៍ ឬអវយវៈសិប្បនិម្មិត និងការព្យាបាលដោយចលនាតែប៉ុណ្ណោះ។ ដោយឡែកការផ្តល់សេវាស្តារលទ្ធភាពពលកម្មផ្នែកវេជ្ជសាស្ត្រមួយចំនួនទៀត, ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងការងារ និងសេវាសង្គមផ្សេងទៀតមិនទាន់បានផ្តល់នៅឡើយទេ។

ទន្ទឹមនឹងការផ្តល់សេវាខាងលើ ជាលទ្ធផលនៅក្នុងឆ្នាំ២០១៦ នេះ ក្រុមការងាររៀបចំយន្តការផ្តល់សេវាបុននីតិសម្បទា បានអនុវត្តនូវការងារមួយចំនួន ដូចខាងក្រោម៖

- សរសេរពីលំហូរការងារ Flow Chart, កំណត់បង្ហាញ, ពាក្យស្នើសុំ, លិខិតបញ្ជូនជនពិការ, ទម្រង់របាយការណ៍ពីប្រព័ន្ធ និងទម្រង់វាយតម្លៃតាមដានពីការផ្តល់សេវា។
- រៀបចំសេចក្តីព្រាងប្រកាសស្តីពីសេវាស្តារនីតិសម្បទា សម្រាប់ផ្នែកធានារ៉ាប់រងហានិភ័យការងារ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ផ្តល់ និងរក្សាទុកសេវាស្តារនីតិសម្បទា
- សហការជាមួយការិយាល័យព័ត៌មានវិទ្យាបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព និងការផ្តល់សេវាស្តារនីតិសម្បទារបស់ ប.ស.ស
- ទូរស័ព្ទទំនាក់ទំនងសួរសុខទុក្ខ និងប្រមូលព័ត៌មានពីកម្មករនិយោជិត ជាសមាជិករបស់ ប.ស.ស ដែលទទួលរងគ្រោះថ្នាក់ការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងាររអចិន្ត្រៃយ៍ ដើម្បីជួយសម្របសម្រួលផ្តល់សេវាស្តារនីតិសម្បទា និងផ្តល់តាវកាលិកជារួម
- សហការជាមួយការិយាល័យតាវកាលិក ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលស្តារលទ្ធ-ភាពពលកម្មកាយសម្បទាចំនួន ១១, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន០១, ក្រុមហ៊ុនផ្តល់សេវាស្តារលទ្ធភាពពលកម្មចំនួន ០១
- សហការជាមួយការិយាល័យថែទាំសុខភាព ចុះពិនិត្យវាយតម្លៃពិការភាព និងតាមដានការផ្តល់សេវាស្តារនីតិសម្បទាផ្ទាល់ ដល់សមាជិក ប.ស.ស ចំនួន ៧៦រូប
- សហការជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មអ្នកជំងឺរបួសខួរឆ្អឹងខ្នង ខេត្តបាត់ដំបង ចុះពិនិត្យកម្មករនិយោជិត ទទួលរងគ្រោះថ្នាក់ការងាររបួសខួរឆ្អឹងខ្នងតាមបណ្តារាជធានី-ខេត្ត និងបានផ្តល់សេវាស្តារនីតិសម្បទាខួរឆ្អឹងខ្នងបានចំនួន ០៤រូប

- សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប ផ្តល់ការបណ្តុះ-បណ្តាលដល់សមាជិក ប.ស.ស បានចំនួន០៥រូប
- សហការជាមួយការិយាល័យតាវកាលិក និងការិយាល័យគោលនយោបាយ ចុះពិនិត្យស្ថានភាពរបួស និងផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិកបានចំនួន ២៩រូប
- ប្រជុំជាមួយមូលនិធិជនពិការ (ម.ជ.ព) ក្រុមហ៊ុន Exceed និងមជ្ឈមណ្ឌលជាតិស្តារ-លទ្ធភាពពលកម្មជនពិការគៀនឃ្លាំង ដើម្បីស្វែងយល់ពីការប្រើប្រាស់សេវាស្តារនីតិ-សម្បទា និងពិភាក្សារៀបចំគោលការណ៍ចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ប្រើប្រាស់សេវា
- សហការធ្វើទម្រង់របាយការណ៍ជាប្រព័ន្ធស្តីពីការប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជ-សាស្ត្រ (Discharge Report) សម្រាប់ផ្នែកធានារ៉ាប់រងហានិភ័យការងារ
- សិក្សាស្វែងយល់ និងចងក្រងពីទិដ្ឋភាពផ្លូវច្បាប់ និងយុទ្ធសាស្ត្រទាក់ទងនឹងការផ្តល់សេវាស្តារនីតិសម្បទារបស់ ប.ស.ស នៅកម្ពុជា និងអន្តរជាតិ
- ចងក្រងករណីសិក្សាការផ្តល់សេវាស្តារលទ្ធភាពពលកម្មចំនួន ១២ ករណី ក្នុងនោះជន-រងគ្រោះ ០៨ករណី, មណ្ឌល ០២ ករណី និងមន្ទីរពេទ្យ ០២ករណី
- ធ្វើសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងាររៀបចំយន្តការផ្តល់សេវា-បុនទីតិសម្បទា និងសេចក្តីសម្រេចស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រី និងបុគ្គលិកនៃក្រុមការងាររៀបចំយន្តការផ្តល់សេវាបុនទីតិសម្បទា
- ចងក្រងព័ត៌មានពីក្រសួង, ស្ថាបន, មជ្ឈមណ្ឌល, អង្គការ និងក្រុមហ៊ុនឯកជនដែលផ្តល់សេវាស្តារនីតិសម្បទា។

## ២. ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

❖ បេឡាជាតិរបបសន្តិសុខសង្គម បានបញ្ចប់គម្រោងធានារ៉ាប់រងសុខភាព (HIP) របស់អង្គការ GRET មកអនុវត្តសាកល្បង ដែលគម្រោងនេះគ្របដណ្តប់លើសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ និងសេវាបញ្ជូនជនរងគ្រោះ នៅត្រឹមបំណាច់ខែមីនា ឆ្នាំ២០១៦ មក។ របបធានារ៉ាប់រងសុខភាពសម្រាប់កម្មកររោង-ចក្រ (HIP) មានសហគ្រាស គ្រឹះស្ថាន ចំនួន ១១ រោងចក្រ មានកម្មករនិយោជិតជាមធ្យម ៤ខែចុងក្រោយសរុប ចំនួន ៦ ៣១២ នាក់ (ស្រី ៥ ៦៨១ នាក់) ក្នុងនោះមានសមាជិកប្រើប្រាស់សេវាសរុបចំនួន ២ ២២៤ដង។

**តារាងទី ១៨៖ ចំនួនអ្នកប្រើប្រាស់សេវាធានារ៉ាប់រងសុខភាព (HIP)**

| ល.រ | ប្រភេទអ្នកប្រើប្រាស់សេវាធានារ៉ាប់រងសុខភាព(HIP) | អ្នកប្រើប្រាស់ (ដង) | | |
|---|---|---|---|---|
| | | ឆ្នាំ2016 | ឆ្នាំ2015 | បម្រែបម្រួល (± %) |
| ១ | សម្រាកនៅពេទ្យ (IPD) | 120 | 417 | -71.22% |
| ២ | ពិគ្រោះជំងឺក្រៅ (OPD) | 2,049 | 10,822 | -81.07% |
| ៣ | សម្រាលកូន (Delivery) | 34 | 121 | -71.90% |
| ៤ | រលូតកូន (Abortion) | 21 | 106 | -80.19% |
| សរុប | | 2,224 | 11,466 | -80.60% |

ប្រភព៖ បេឡាជាតិ របបសន្តិសុខសង្គម ឆ្នាំ 2016

## ២.១. ការចារបញ្ជិកា និងភាគទាន

### ២.១.១. ការចារបញ្ជិកា (ការកំណត់អត្តសញ្ញាណកម្មករនិយោជិត)

ផ្អែកតាមប្រកាសលេខ០៩៣ កប/ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ដំណាក់កាលនិងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងសេចក្តីជូនដំណឹងលេខ ១២៧ កប/ស.ជ.ណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុង ប.ស.ស ក្នុងទិសដៅនេះ ប.ស.ស បានកំណត់ការអនុវត្តដោយផ្តើមចេញពីសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឈានទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។

ប.ស.ស បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញត្រឹមខែធ្នូ ឆ្នាំ២០១៦ នេះ បាន ចំនួន ៦០៣សហគ្រាស មានកម្មករនិយោជិតចំនួន ៦០០ ៨៣១នាក់ ស្រី ៥០៤ ៤៥៦នាក់។

**តារាងទី ១៩. កំណត់អត្តសញ្ញាណកម្មករនិយោជិតជាថ្មី**

| បរិយាយ | កំណត់អត្តសញ្ញាណកម្មករនិយោជិតជាថ្មី | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ថ្នាក់កណ្តាល (រាជធានីភ្នំពេញ) | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ត្រឹមខែធ្នូ ឆ្នាំ2016 | 603 | 600,831 | 504,456 | 390 | 374,008 | 305,309 | 213 | 226,823 | 199,147 |
| បច្ចុប្បន្នភាពសហគ្រាសនិងកម្មករ-និយោជិត ឆ្នាំ2016 | 6,884 | 1,108,759 | 752,459 | 3,832 | 611,064 | 396,987 | 3,052 | 497,695 | 355,472 |
| ផលធៀប (%) | 8.76% | 54.19% | 67.04% | 10.18% | 61.21% | 76.91% | 6.98% | 45.57% | 56.02% |

**តារាងទី ២០. ការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត ផលធៀបនិងសហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល (រាជធានីភ្នំពេញ) | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ត្រឹមខែធ្នូ ឆ្នាំ2016 | 603 | 600,831 | 504,456 | 390 | 374,008 | 305,309 | 213 | 226,823 | 199,147 |
| បច្ចុប្បន្នភាពសហគ្រាសវិស័យកាត់ដេរ និងស្បែកជើងឆ្នាំ2016 | 1,006 | 687,686 | 566,645 | 646 | 362,001 | 298,371 | 360 | 325,685 | 268,274 |
| ផលធៀប (%) | 59.94% | 87.37% | 89.03% | 60.37% | 103.32% | 102.33% | 59.17% | 69.64% | 74.23% |

ផ្អែកតាមតារាងទី១៩ ការធ្វើផលធៀបរវាងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើង-វិញ ធៀបនឹងបច្ចុប្បន្នភាពសហគ្រាសចុះបញ្ជិកា សម្រេចបាន ៨,៧៦ភាគរយ។ ដោយឡែកផ្អែកតាមតារាងទី ២០ ផលធៀបរវាងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ ធៀបនឹងបច្ចុប្បន្នភាពសហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើងឃើញថាលទ្ធផលនៃការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញសម្រេចបាន ៥៩,៩៤ភាគរយ។

### ២.១.២. ការចារភាគទាន

ផ្អែកតាមប្រកាសលេខ ២២០ កប/ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស នឹងដាក់លិខិតឱ្យសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជាប់ភាគទានចាប់ពីខែកញ្ញា ឆ្នាំ២០១៦ តទៅ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលភាគទាន និងបង់ភាគទាន មក ប.ស.ស។ អត្រាភាគទានរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ស្មើនឹង ១,៣

(មួយក្បៀសបី) ភាគរយ និងកម្មករនិយោជិតក៏ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយដែរ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់ នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

នៅក្នុងឆ្នាំ២០១៦ ប.ស.ស បានដាក់ឲ្យជាប់ភាគទាន ចំនួន ៣៤៥ សហគ្រាស ក្នុងនោះ សហគ្រាស បានបង់ភាគទាន មានចំនួន ៣១២សហគ្រាស មានកម្មករនិយោជិតចំនួន ២៨២.៧២៧ នាក់ ស្រី ២៣៦.០៥០នាក់។

តារាងទី ២១៖ ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត បានបង់ភាគទាន

| បរិយាយ | សហគ្រាស ជាប់ភាគទាន | សហគ្រាស បានបង់ភាគទាន | កម្មករនិយោជិត | | សហគ្រាស មិនបានបង់ភាគទាន | កម្មករនិយោជិត | |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | សរុប | ស្រី |
| ខែកញ្ញា ឆ្នាំ២០១៦ | 240 | 234 | 224,804 | 188,780 | 6 | 3,271 | 2,446 |
| ខែតុលា ឆ្នាំ២០១៦ | 314 | 300 | 289,751 | 241,910 | 14 | 7,365 | 5,701 |
| ខែវិច្ឆិកា ឆ្នាំ២០១៦ | 345 | 312 | 282,727 | 236,050 | 33 | 26,941 | 21,952 |
| **សរុប(មធ្យមភាគ)** | **300** | **282** | **265,761** | **222,247** | **53** | **37,577** | **30,099** |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៦

តារាងទី ២១.១. បច្ចុប្បន្នភាព ភាគទាន

| បច្ចុប្បន្នភាពភាគទាន | | |
|---|---|---|
| ឆ្នាំ ២០១៦ (លានរៀល) | ឆ្នាំ ២០១៥ (លានរៀល) | បម្រែបម្រួល (± %) |
| 17,048.96 | N/A | #VALUE! |

## ២.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

- សហការចុះទៅពន្យល់ណែនាំពីនីតិវិធីចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតឡើងវិញ
- សហការចុះទៅពន្យល់ណែនាំពីតាវកាលិកថែទាំសុខភាព និងការបង់ភាគទាន
- សហការចុះចែកលិខិតឱ្យសហគ្រាស គ្រឹះស្ថានជាប់ភាគទាន
- ចុះទៅសម្របសម្រួល (ចុះបើកផ្លូវ) តាមបណ្តាសហគ្រាសគ្រឹះស្ថាននៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន។ លទ្ធផលសហគ្រាសដែលបានចុះសម្របសម្រួល (ចុះបើកផ្លូវ) ទាំងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួនក្នុងឆ្នាំ២០១៦ នេះ បានចំនួន ៥៤៧ សហគ្រាស គ្រឹះស្ថាន។

## ២.៣. ការផ្តល់សេវាតាវកាលិក

ដើម្បីឱ្យកម្មករទទួលបានសេវាដែលនៅជិតកន្លែងការងារ និងលំនៅស្ថាន ក្នុងដំណាក់កាលនេះ ប.ស.ស បានពង្រីកវិសាលភាពចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី-ខេត្ត គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ ចំនួន *៧៨៣* មូលដ្ឋាន រួមមានមន្ទីរពេទ្យថ្នាក់ជាតិចំនួន០៣ មន្ទីរពេទ្យបង្អែកចំនួន ១០០ មណ្ឌលសុខភាព ចំនួន*៦៨០*។

សមាជិកទៅទទួលសេវាថែទាំសុខភាព គិតពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ សរុបចំនួន ១៧.០៤៥ នាក់ ស្រី ១៥.០៤៧នាក់ ក្នុងនោះអនុញ្ញាតឱ្យទទួលសេវា ចំនួន ១៦.០៦៣ នាក់ ស្រី ១៤.៦៥០នាក់ និងមិនបានទទួលសេវា ចំនួន ៩៨២ នាក់ ស្រី ៣៩៧នាក់ (មូលហេតុដែលមិនអាចទទួលសេវាបានព្រោះកម្មករនិយោជិត ទាំងនោះមិនទាន់បានបំពេញគ្រប់លក្ខខណ្ឌ)។

## ៣. ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

ការរៀបចំបង្កើតឱ្យមានរបបប្រាក់សោធន សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលចំពោះអនាគត នៃកម្លាំងពលកម្មសកម្ម នាពេលបច្ចុប្បន្ន និងម្យ៉ាងទៀតក៏ជាការរួមចំណែកលើកកម្ពស់ផលិតភាពពលកម្មផងដែរ ព្រោះថាតាមរយៈយន្តការនេះកម្មករ-និយោជិត ដែលជាកម្លាំងពលកម្មសកម្មនឹងមានភាពកក់ក្តៅក្នុងចិត្តចំពោះអនាគតរបស់ខ្លួនទោះបីជាកំពុងធ្វើការក្នុងវិស័យឯកជនក្តី ក៏ពួកគេអាចមានលទ្ធភាពរស់នៅដោយខ្លួនឯងបាននៅពេលជរាភាព ដោយមិនអាស្រ័យទាំងស្រុងលើការចិញ្ចឹមជីវិតពីកូនចៅនោះឡើយ។ ចំណុចនេះគឺជាផ្នែកមួយលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ជនចាស់ជរា។

ផ្នែកប្រាក់សោធននេះ ត្រូវបានថ្នាក់ដឹកនាំ កំណត់ដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៧ ដែលបច្ចុប្បន្នក្រុមការងាររៀបចំ បាននិងកំពុងសិក្សាបទដ្ឋានគតិយុត្ត ដែលឈានដល់ការរៀបចំសមិទ្ធលទ្ធភាពដាក់ឱ្យដំណើរការដោយការរំពឹងទុក និងគ្មានផលប៉ះពាល់។

## ៤. ការងារគាំទ្រការអនុវត្ត

### ៤.១. ការងាររៀបចំគោលនយោបាយ និងលិខិតគតិយុត្ត

ការកើនឡើងនូវទំហំការងារ ចំនួនសមាជិក ស្ថានភាពនៃការរីកចម្រើនសេដ្ឋកិច្ចសង្គម និងតម្រូវការនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ និយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ប.ស.ស ឆ្នាំ២០១៦នេះបានខិតខំប្រឹងប្រែងបំពេញការងារទ្វេឡើង ដោយបានរៀបចំពង្រឹង ពង្រីក និងអភិវឌ្ឍន៍គោលន-យោបាយរបបសន្តិសុខសង្គម តាម-រយៈ ការរៀបចំផែនការរយៈពេលវែងដែលមានលក្ខណៈស៊ីជម្រៅ និងការកសាងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ដើម្បីធានាក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាពទាន់ពេលវេលា និងឆ្លើយតបតាមតម្រូវការ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ប្រព្រឹត្តទៅបានចំនួន ១០ លើក (លើកទី២៦ ,២៧, ២៨, ២៩, ៣០, ៣១, ៣២, ៣៣, ៣៤ និងទី៣៥) នៃអាណត្តិទី៣ និងប្រជុំបានចំនួន ០៣លើក ក្នុងអាណត្តិទី៤ នេះ បានពិនិត្យសម្រេច និងអនុម័តព្រមទាំងទទួលបានការឯកភាព យល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ រួមមាន៖

*រូបភាពទី២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃ ប.ស.ស លើកទី០២ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦*



- ពិនិត្យរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត និងគម្រោងដាក់ឱ្យដំណើរការរបបថែទាំសុខភាព នៃ ប.ស.ស

- ពិនិត្យលើសេចក្តីព្រាងប្រកាសស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ពិនិត្យលើសេចក្តីព្រាងប្រកាសស្តីពីតារាកាលិកថែទាំសុខភាព
- ពិនិត្យលើសេចក្តីព្រាងប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព
- ពិនិត្យលើសេចក្តីព្រាងប្រកាសរួមស្តីពីយន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព
- ពិនិត្យលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាង ប.ស.ស និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព
- ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៥ របស់បេឡាជាតិរបបសន្តិសុខសង្គម
- ពិនិត្យលើសេចក្តីព្រាងប្រកាសស្តីពីបញ្ជីជំងឺរ៉ាំរ៉ៃ
- ពិនិត្យលើសេចក្តីព្រាងផែនការចំណូល-ចំណាយរបស់ ប.ស.ស ឆ្នាំ២០១៧
- ពិនិត្យកែសម្រួលកម្រិតពិដាន (Ceiling Rate) ដែលត្រូវជាប់ភាគទាន
- ពិនិត្យលើរបាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានរយៈពេល៩ខែ របស់ក្រុមការងារ ទ.ស.ប.ក និងក្រុមការងារ ស.ផ.ក។

## ៤.២. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

### ៤.២.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

#### ៤.២.១.១. ការងាររដ្ឋបាល

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រង មន្ត្រី បុគ្គលិក ដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។

នៅឆ្នាំ២០១៦ កន្លងមកនេះ រដ្ឋបាលរបស់ ប.ស.ស សម្រេចបានៈ

- គ្រប់គ្រងលិខិតចូលសរុបបាន ៧៨២ លេខ
- គ្រប់គ្រងលិខិតចេញសរុបបាន ១.១៨០ លេខ
- រៀបចំទូទាត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗជូនមន្ត្រី និងបុគ្គលិកសម្រាប់ ខែធ្នូ ឆ្នាំ២០១៥ ដល់ខែវិច្ឆិកា ឆ្នាំ២០១៦
- រៀបចំបង់ភាគទានផ្នែកហានិភ័យការងារ ដល់បុគ្គលិកក្នុងឆ្នាំ២០១៦ ចំនួន ៦០៥នាក់
- កែតម្រូវប្រាក់បៀវត្សរបស់ លោក ហាត ទៀនបូរេន នៅក្នុងតារាងប្រាក់កម្រៃលើកទឹកចិត្ត
- តម្លើងកម្រិតមុខងារ និងប្រាក់កម្រៃលើកទឹកចិត្ត ជូនមន្ត្រីរាជការ ចំនួន០៦រូប ប្រចាំប.ស.ស

- រៀបចំសំណើសុំគោលការណ៍អនុញ្ញាតជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន ៥០នាក់ សម្រាប់ចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិតថ្មី ប្រចាំបេឡាជាតិរបបសន្តិសុខសង្គម
- បញ្ចូលបេក្ខជនសាកល្បងការងារ ចំនួន ១៤៥រូប នៅទីស្នាក់ការកណ្តាល និងសាខាខេត្តព្រៃវែង, បាត់ដំបង, កំពត, កោះកុង, បន្ទាយមានជ័យ, ប៉ៃលិន, ពោធិ៍សាត់, កំពង់ស្ពឺ និងខេត្តស្វាយរៀង
- បញ្ចូលបុគ្គលិកឱ្យពេញសិទ្ធិ ចំនួន៧៤រូប នៅទីស្នាក់ការកណ្តាល និងសាខាខេត្តបាត់ដំបង, កំពង់ធំ, សៀមរាប, ព្រៃវែង, តាកែវ, រតនគិរី, កំពង់ឆ្នាំង និងក្រចេះ
- បន្តកិច្ចសន្យាការងារថ្មីរយៈពេល ១ឆ្នាំដល់បុគ្គលិក ចំនួន ៨២រូប នៅទីស្នាក់ការកណ្តាល និងសាខាខេត្តពោធិ៍សាត់, កំពត, តាកែវ, ព្រះសីហនុ, កំពង់ឆ្នាំង, ស្វាយរៀង, បន្ទាយមានជ័យ, កោះកុង, កំពង់ធំ, សៀមរាប, ឧត្តរមានជ័យ, ប៉ៃលិន, មណ្ឌលគិរី, ព្រៃវែង, កំពត, កំពង់ចាម, រតនគិរី, ក្រចេះ និងកណ្តាល
- តម្លើងថ្នាក់ និងប្រាក់កម្រៃលើកទឹកចិត្ត ជូនបុគ្គលិកជាប់កិច្ចសន្យាការងារ ចំនួន ១៨រូប ដែលបានបម្រើការងារអស់រយៈពេល០២ឆ្នាំ ប្រចាំ ប.ស.ស
- រៀបចំប្រជុំវាយតម្លៃបុគ្គលិកសាកល្បងការងារ ចំនួន ៦២រូប ស្នើដាក់ឱ្យពេញសិទ្ធិជាបុគ្គលិកជាប់កិច្ចសន្យារយៈពេល ០១ឆ្នាំ ប្រចាំ ប.ស.ស
- ទូទាត់ថ្លៃជួលអគារ និងថ្លៃប្រើប្រាស់ទឹកភ្លើងនៅសាខាខណ្ឌ/ខេត្ត។

### ៤.២.១.២. ការងារហិរញ្ញវត្ថុ

ការងារគណនេយ្យ និងកិច្ចការហិរញ្ញវត្ថុ របស់ ប.ស.ស ប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារទាំងស្រុង ពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និងចំណាយ មានជាអាទិ៍ ការប្រមូលភាគទានពីសហគ្រាស គ្រឹះស្ថាន, ការបង់ប្រាក់ពិន័យ, ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យការងារ និងការចំណាយរដ្ឋបាល ត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធនាគារ។ ក្នុងគោលដៅធានាពីប្រសិទ្ធភាព និងគណនេយ្យភាព។ ក្នុងដំណើរការនៃកិច្ចប្រតិបត្តិការ ប.ស.ស បានអនុវត្តនូវការងារសំខាន់ៗ មួយចំនួនដូចខាងក្រោម ៖

- រៀបចំផែនការចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់(លើកទិសដៅអនុវត្ត)
- រៀបចំរបាយការណ៍ចំណូល និងចំណាយសាច់ប្រាក់លម្អិតប្រចាំខែក្នុងឆ្នាំ២០១៦
- កត់ត្រាចំណូលភាគទានប្រចាំខែ ដែលបានមកពីការប្រមូលភាគទានតាមរោងចក្រសហគ្រាស នីមួយៗនៅក្នុង Account Receivable
- កត់ត្រាចំណាយប្រចាំថ្ងៃនៅក្នុង Journal Entry
- កត់ត្រាចំណាយជំពាក់ជាសាច់ប្រាក់ប្រចាំខែ សម្រាប់អង្គភាពផ្គត់ផ្គង់ដូចជាថ្លៃព្យាបាលនៅតាមមន្ទីរពេទ្យនីមួយៗ និងតាវកាលិកធនលាភដែលសមាជិក ប.ស.ស ទទួលបានក្នុង Account Payable

- រៀបចំអត្រាប្តូរប្រាក់សម្រាប់ភាគទានប្រចាំខែនីមួយៗ
- ពិនិត្យចំណាយផ្សេងៗដូចជា ចំណាយបេសកកម្ម, ចំណាយរដ្ឋបាល, ចំណាយបង្ការហានិភ័យការងារ និងចំណាយតាវកាលិក
- រៀបចំបង់ពន្ធលើប្រាក់លើកទឹកចិត្តប្រចាំខែនីមួយៗ
- រៀបចំបញ្ជីបើកប្រាក់បៀវត្សប្រចាំខែនីមួយៗ
- ផ្ទៀងផ្ទាត់របាយការណ៍ធនាគារជាមួយសៀវភៅបេឡា។

## ៤.២.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ជាការងារមួយសំខាន់នៅក្នុងការអភិវឌ្ឍអង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីធានានូវនិរន្តភាពនៃកិច្ចដំណើរការរបស់អង្គភាព លើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារ ក៏ដូចជាការអភិវឌ្ឍនូវចំណេះដឹង ការដកស្រង់ និងផ្លាស់ប្តូរបទពិសោធន៍ការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឱ្យមានការរីកចម្រើនផងដែរ ដែលថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រី ប.ស.ស បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដូចខាងក្រោម៖

### ៤.២.២.១. ការងារក្នុងប្រទេស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស ប.ស.ស បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងធ្វើបច្ចុប្បន្នភាពការងារផ្ទៃក្នុងដល់មន្ត្រី និងបុគ្គលិកជាប្រចាំរៀង-រាល់ឆ្នាំ។ ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៃ ប.ស.ស បានរៀបចំ និងចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពិភាក្សាការងារ ការរៀបចំផែនការអភិវឌ្ឍន៍ និងសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងតាមបណ្តាក្រសួង អង្គការ និងស្ថាប័នពាក់ព័ន្ធនានានៅទូទាំងប្រទេសជាច្រើនលើករួមមាន៖

- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីការធ្វើបច្ចុប្បន្នភាពការងារជំនាញផ្នែកអធិ-ការកិច្ច និងផ្នែកថែទាំសុខភាពដល់មន្ត្រី និងបុគ្គលិកតាមខេត្តទាំង២៣ខេត្ត និង ០២ខណ្ឌ
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីការធ្វើបច្ចុប្បន្នភាពនីតិវិធីនៃការចុះបញ្ជិកា និងបង់ភាគទានផ្នែកថែទាំសុខភាព ដល់មន្ត្រី និងបុគ្គលិកតាមបណ្តាខេត្តទាំង ២៣ខេត្ត និង០២ខណ្ឌ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ពីប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវា និងកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវាសុខាភិបាលរវាង ប.ស.ស និងមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព
- ចូលរួមសិក្ខាសាលាស្តីពីការអនុវត្តចំណាយឆ្នាំ២០១៦ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ចូលរួមសិក្ខាសាលាស្តីពី គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យប្រចាំគ្រឹះស្ថាន សាធារណរដ្ឋបាល នៅទីស្តីការក្រសួងសេដ្ឋកិច្ច
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីហិរញ្ញប្បទានសោធន នៅទីស្តីការក្រសួងសេដ្ឋកិច្ច
- ចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ នៅធនាគារជាតិនៃកម្ពុជា។
- ចូលរួមក្នុងសិក្ខាសាលាស្តីពី ការធានារ៉ាប់រងសុខភាពសង្គមសម្រាប់ប្រជាពលរដ្ឋក្នុងសេដ្ឋកិច្ចក្រៅប្រទេស នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសហជីព នៅវិមានរដ្ឋសភា
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអំពី គម្រោងអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព នៅសណ្ឋាគារភ្នំពេញ
- ចូលរួមក្នុងសិក្ខាសាលាស្តីពី ការវាយតម្លៃសមត្ថភាព និងការកសាងផែនការសកម្មភាពឆ្នាំ២០១៦ របស់អង្គការ GIZ នៅសណ្ឋាគារ Imperial Garden Villa
- ចូលរួមសិក្ខាសាលាស្តីពី លទ្ធផលបូកសរុបការងារការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកប្រចាំត្រីមាសទី១ នៅក្រសួងសាធារណការ និងដឹកជញ្ជូន
- ចូលរួមសិក្ខាសាលាស្តីពី ការពិគ្រោះយោបល់ពិភាក្សាលើពង្រាងគោលការណ៍ណែនាំថ្នាក់ជាតិ កញ្ចប់អត្ថប្រយោជន៍ និងយន្តការបង់ថ្លៃសេវាសម្រាប់មូលនិធិសមធម៌ នៅសណ្ឋាគារសាន់វេ (ភ្នំពេញ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ស្តីពីកម្មវិធីការងារសមរម្យសម្រាប់កម្ពុជា ឆ្នាំ២០១៦-២០១៨ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈ នៅប្រទេសកម្ពុជា នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលអំពីនីតិវិធីនៃការផ្តល់តាវកាលិកហានិភ័យការងារ និងការសម្របសម្រួលមន្ទីរពេទ្យ ដែលមានមន្ត្រី ចំនួន១២រូប និងបុគ្គលិក ចំនួន៣៣រូប។
- ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំគម្រោងថវិកាកម្មវិធីសម្រាប់ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី PQI ការពង្រឹងគុណភាព និងផលិតភាពការងារ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពជនបង្គោលយេនឌ័រតាមអង្គ-ភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាកសាងសមត្ថភាពថ្នាក់ជាតិស្តីពី ការរៀបចំផែនការសកម្មភាពផ្តល់ការយល់ដឹងអំពីនីតិវិធីស្នើសុំថវិកា និងអំពីថវិកាកម្មវិធីឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ក្រោមកិច្ចសហការជាមួយអង្គការ (ILO) នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Crisis Management and Disaster Risk Reduction នៅមជ្ឈមណ្ឌលកម្ពុជា-សឹង្ហបុរី
- ចូលរួមសិក្ខាសាលាលើកទីពីរស្តីពី ការស្រាវជ្រាវសុខភាពនៅកម្ពុជា នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី
- ចូលរួមសិក្ខាសាលាស្តីពី Bong Market Development in Emerging East Asia នៅសណ្ឋាគារ រ៉ាហ្វលឡឺរ៉ូយ៉ាល់
- ចូលរួមសិក្ខាសាលាត្រីភាគីថ្នាក់ជាតិស្តីពី ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ដំណើរការតាក់តែងពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ដើម្បីអភិបាលកិច្ចល្អ ការផ្លាស់ប្តូរជាវិជ្ជមាន និងការដោះស្រាយ បណ្តឹងតវ៉ា-វិវាទក្រៅប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាព នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ នៅសាលប្រជុំសាលាខណ្ឌសែនសុខ
- ចូលរួមប្រជុំពិភាក្សា និងការរៀបចំវគ្គបណ្តុះបណ្តាលទៅដល់គ្រូបង្គោល និងក្រុមការងារចុះផ្សព្វផ្សាយដោយអនុលោមតាមសេចក្តីសម្រេចលេខ ២ គ.ក.ប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ នៅសាលប្រជុំ ប.ស.ស
- ចូលរួមសិក្ខាសាលា ស្តីពីដំណើរការរៀបចំក្របខណ្ឌច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម នៅសណ្ឋាគារ SUNWAY
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធព្យាករណ៍ការបំពុលពីរោងចក្រ និងសហគ្រាស នៅសណ្ឋាគារសុខា
- ចូលរួមសិក្ខាសាលា ស្តីពីឧបករណ៍វិភាគលទ្ធផលនៃការវិនិយោគទៅលើសុខភាពបន្តពូជ និងផែនការគ្រួសារ នៅសណ្ឋាគារកាំបូឌីយ៉ាណា

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ប៉ាន់ស្មានការចំណាយលើការថែទាំសុខភាពនៅកម្ពុជាឆ្នាំ២០១២-២០១៤។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ នៅសណ្ឋាគារសាន់វេ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេក្តីព្រាងអនុក្រឹត្យ ស្តីពីការធានារ៉ាប់-រងខ្នាតតូច នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពីសោធន នៅសណ្ឋាគារ Rock Royal
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី០១ លើសេក្តីព្រាងគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលា ស្តីពីកិច្ចការរដ្ឋបាល បុគ្គលិក និងផែនការ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី០២ លើសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលា ស្តីពីការយល់ដឹងអំពីកិច្ចគាំពារសង្គម នៅភោជនីយដ្ឋានទន្លេបាសាក់II
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីចំណាយតាមរដ្ឋ-ទេយ្យបុរេប្រទាន សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅទីស្តីការក្រសួងការ-ងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី Improving the Efficiency of Health and Disease Spending with an Emphasis on the Role of Health Financing នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី Purchasing to round out the Overall Materials on three Health Financing, Re-Insurance, and Provider Payment Mechanism នៅសណ្ឋាគារសុខា ខេត្តសៀមរាប

ក្រៅពីការងារខាងលើ ប.ស.ស ក៏បានចាត់បញ្ជូនមន្ត្រី និងបុគ្គលិកឱ្យចូលរួមនៅក្នុងសកម្មភាពការងារសង្គមជាច្រើនលើក ដើម្បីរួមចំណែកនៅក្នុងការអភិវឌ្ឍសង្គមជាតិទាំងមូលផងដែរ។

#### ៤.២.២.២. ការងារក្រៅប្រទេស

ក្រៅពីការងារលើកកម្ពស់ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ការទំនាក់ទំនងក្រៅប្រទេសជាការងារមួយដ៏សំខាន់ នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍បរទេសនានា និងការធ្វើសមាហរណកម្មវិស័យសន្តិសុខសង្គមរបស់កម្ពុជាទៅក្នុងតំបន់ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍ បច្ចេកទេសការងារថ្មីៗ យកមកធ្វើការអភិវឌ្ឍនៅក្នុងប្រទេស។ ឆ្នាំ២០១៦

នេះ ប.ស.ស បានបំពេញនូវការងារក្រៅប្រទេសសំខាន់ៗមួយចំនួនសម្រាប់វិស័យសន្តិសុខសង្គម ដូចខាងក្រោម៖

- ចូលរួមសិក្ខាសាលាស្តីពីការវិនិយោគ នៃបេឡាជាតិរបបសន្តិសុខសង្គម នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី
- ចូលរួមទស្សនកិច្ចសិក្សាស្តីពីការគាំពារសុខភាពជាសកល នៅប្រទេសជប៉ុន
- ចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធការងារសុខភាពសង្គម នៅទីក្រុងបាងកក ប្រទេសថៃ
- ចូលរួមសិក្ខាសាលាស្តីពី របបសន្តិសុខសង្គម នៅប្រទេសអាល្លឺម៉ង់
- ចូលរួមសិក្ខាសាលាស្តីពី ការគាំពារសន្តិសុខសង្គមអន្តរជាតិ នៅទីក្រុងស៊ីប៊ូ ប្រទេសហ្វីលីពីន
- ចូលរួមសិក្ខាសាលាស្តីពី កម្មវិធីកសាងសមត្ថភាពផ្នែកព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ
- ចូលរួមកម្មវិធីស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ការគ្របដណ្តប់សេវាសុខភាពជាសកលដែលរៀបចំដោយ GIZ និងធនាគារពិភពលោក នៅទីក្រុងស៊ីប៊ូ ប្រទេសហ្វីលីពីន
- ចូលរួមវគ្គបណ្តុះបណ្តាលអន្តរជាតិស្តីពី សេវាបុននីតិសម្បទា សម្រាប់កម្មករដែលបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ នៅប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ធានារ៉ាប់រងសុខភាព នៅសាធារណរដ្ឋកូរ៉េ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ការគ្របដណ្តប់សេវា-សុខភាពជាសកលដែលរៀបចំដោយ GIZ និងធនាគារពិភពលោក នៅប្រទេសម៉ាឡេស៊ី
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការការពារសន្តិសុខសង្គម នៅប្រទេសម៉ាឡេស៊ី
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣៣ របស់សមាគមសន្តិសុខសង្គមអាស៊ាន នៅប្រទេសហ្វីលីពីន
- ចូលរួមសិក្ខាសាលាស្តីពីការវិនិយោគ នៃបេឡាជាតិរបបសន្តិសុខសង្គម នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- ចូលរួមសិក្ខាសាលាលក្ខណៈទ្វេតំបន់ របស់អង្គការសុខភាពពិភពលោក ស្តីពីគោលនយោបាយហិរញ្ញប្បទានសុខាភិបាលនៅអាស៊ី នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- ចូលរួមសិក្ខាសាលាស្តីពី ការគាំពារសង្គមជាសកលតាមរយៈកិច្ចសហប្រតិបត្តិការត្រីភាគីរវាងប្រទេសកំពុងអភិវឌ្ឍន៍ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមា-និតចិន
- ចូលរួមទស្សនកិច្ចសិក្សា ស្តីពីការកំណត់អត្តសញ្ញាណបុគ្គលិក នៅប្រទេសជប៉ុន
- ចូលរួមសិក្ខាសាលា ស្តីពីការធានារ៉ាប់រងគ្រោះថ្នាក់ការងារ នៅសាធារណរដ្ឋកូរ៉េ

- ចូលរួមវេទិកាសន្និបាតសាកល ស្តីពីការទូទាត់សំណងគ្រោះថ្នាក់ការងារអាស៊ី នៅប្រទេសម៉ាឡេស៊ី
- ចូលរួមសិក្ខាសាលា ស្តីពីសក្តានុពលនៃកិច្ចគាំពារសង្គម ដើម្បីបង្កើនភាពធន់ទៅនឹងគ្រោះមហន្តរាយ នៅប្រទេសហ្វីលីពីន
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីគំរូនៃការគណនាតម្លៃក្នុងរបបសោធននិវត្តសាធារណៈ នៅប្រទេសអ៊ីតាលី

## ៤.២.៣. ការងារព័ត៌មានវិទ្យា

ប.ស.ស បានរៀបចំកិច្ចប្រតិបត្តិការងារ និងការគ្រប់គ្រងទិន្នន័យតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាលើការងារចុះបញ្ជិកា, បង់ភាគទាន, ការផ្តល់តាវកាលិក, ការគ្រប់គ្រងវត្តមានមន្ត្រី និងការងារសំខាន់ៗមួយចំនួនទៀត ជាក់ស្តែងនៅឆ្នាំ២០១៦ ប.ស.ស សម្រេចបានលើការងារព័ត៌មានវិទ្យា ដូចខាងក្រោម៖

### ៤.២.៣.១. ផ្នែក Programming

**កម្មវិធីទាញទិន្នន័យទៅកាន់កម្មវិធី Sage Accpac (Nssf Sage)៖**

- អភិវឌ្ឍន៍កម្មវិធី Nssf Sage ដើម្បីទាញចំណូលការបង់ភាគទាន និងបង្កើតទម្រង់ General Ledger ដើម្បីទាញចំណាយតាវកាលិក ព្រមទាំងចំណាយលើផ្នែកថែទាំសុខភាព
- បង្កើតទម្រង់ Account Receivable ដើម្បីទាញចំណូលផ្នែកបង់ភាគទាន
- ធ្វើការ Backup Data base NSDATE និង Database NSSYS រួច Restore Database ទាំងពីរឡើងវិញដើម្បីធ្វើជា Database សម្រាប់តេស្តសាកល្បងជាមួយកម្មវិធី Sage Accpac និង NSSF Sage ព្រមទាំងធ្វើការដំឡើងកម្មវិធី Sage Accpac នៅលើម៉ាស៊ីន Sever Test និងម៉ាស៊ីន Client ធ្វើតេស្តសាកល្បងជាមួយការិ.គណនេយ្យ។

**កម្មវិធីបោះពុម្ពកាតសមាជិក ប.ស.ស៖**

- ធ្វើបច្ចុប្បន្នភាពទម្រង់បញ្ចូលសមាជិកទទួលកាតរួចហើយ និងទម្រង់បោះពុម្ពកាតតាមលេខអត្តសញ្ញាណ ប.ស.ស ដើម្បីឲ្យដំណើរការបានលឿនជាងមុន
- បង្កើតទម្រង់កែប្រែសហគ្រាសរបស់សមាជិក ប.ស.ស ថ្មី។

**កម្មវិធីទាញទិន្នន័យជា CSV FILE ទៅកាន់ប្រព័ន្ធ HSPIS៖**

- ធ្វើបច្ចុប្បន្នភាពទម្រង់ទាញទិន្នន័យជា CSV File ដោយបន្ថែមការទាញទិន្នន័យរបស់សមាជិក ដែលអ្នកប្រើប្រាស់បញ្ចូលតារាងសមាជិក ដែលមានប្រាក់បៀវត្សបន្ថែមពីលើតារាងដែលបានបញ្ចូលរួចហើយ
- បន្ថែមការទាញទិន្នន័យសហគ្រាស ដែលជាប់ក្នុងរបបថែទាំសុខភាព ពីប្រព័ន្ធទិន្នន័យកម្មវិធីបញ្ជិកា និងភាគទានទៅកាន់ប្រព័ន្ធ HSPIS។

**កម្មវិធីទាញទិន្នន័យបង់ភាគទានតាម ACLEDA UNITY៖** បន្ថែមមុខងារសម្រាប់ធ្វើការគណនាចំនួនកម្មករនិយោជិតដែលត្រូវបង់ភាគទាននៅខែបន្ទាប់។

**កម្មវិធីកំណត់អត្តសញ្ញាណសមាជិក ប.ស.ស៖**

- បង្កើតទម្រង់ផ្នែក Server Application និង Client Application
- លុបទិន្នន័យរួចទាញទិន្នន័យដូចជាឈ្មោះបុគ្គលិក និងចំនួនសហគ្រាសនៃការិ.បញ្ជិកា និងភាគទាន ដើម្បីបញ្ចូលក្នុង Database វិញ
- បង្កើតគណនីថ្មីសម្រាប់បុគ្គលិកចុះកំណត់អត្តសញ្ញាណថ្មី នៃការិ.បញ្ជិកា និងភាគទាន
- គ្រប់មេម៉ាស៊ីនកុំព្យូទ័រត្រូវបានដាក់ Database ថ្មី និងរាល់ម៉ាស៊ីនតាមក្រុមបានដំឡើងកម្មវិធីសម្រាប់កំណត់អត្តសញ្ញាណថ្មីរួចហើយ
- បង្កើតទម្រង់បញ្ចូលព័ត៌មានសហគ្រាស ដែលបានចុះបញ្ជិកាថ្មី ទៅក្នុងប្រព័ន្ធ
- បង្កើតទម្រង់ទាញទិន្នន័យជា File Access ដោយយោងតាមលេខអត្តសញ្ញាណសហគ្រាស និងកាលបរិច្ឆេទបញ្ចូលទិន្នន័យ។

**កម្មវិធីស្នើសុំសេវាស្តារលទ្ធភាពពលកម្ម** (NSSF Rehabilitation)៖

- បង្កើត Database សម្រាប់ផ្ទុកទិន្នន័យ និងទាញយកទិន្នន័យជនរងគ្រោះបាត់បង់-សមត្ថភាពអចិន្ត្រៃយ៍លើសពី ២០%
- កែសម្រួលលំហូរការងារលើផ្នែកស្នើសុំសេវាស្តារលទ្ធភាពពលកម្ម, របាយការណ៍ស្នើសុំសេវាស្តារលទ្ធភាពពលកម្ម, បង្ហាញកម្រិតបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងទម្រង់របាយការណ៍ស្នើសុំសេវាស្តារពលកម្ម
- ដំឡើងកម្មវិធីស្តារលទ្ធភាពពលកម្ម និង Database នៅលើម៉ាស៊ីន Server Testing ដើម្បីឲ្យក្រុមការងារធ្វើការប្រើប្រាស់សាកល្បង
- ធ្វើបច្ចុប្បន្នភាពលើទម្រង់ព័ត៌មានគ្រោះថ្នាក់ ពិការភាព និងលើទម្រង់ប្រវត្តិនៃការទទួលសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ និងការទទួលសេវាស្តារលទ្ធភាពពលកម្ម។

**កម្មវិធីតាវកាលិក** (NSSF Benefit)៖

- ធ្វើបច្ចុប្បន្នភាពផ្នែកការទូទាត់ថ្លៃព្យាបាលតាមមន្ទីរពេទ្យ, កម្មវិធីកែលម្អទម្រង់ធ្វើដីកាអមបញ្ជូនរបាយការណ៍ហានិភ័យការងារ និងកម្មវិធី NSSF Benefit សម្រាប់ការប្រើប្រាស់លេខអត្តសញ្ញាណ ប.ស.ស ថ្មី១៥ខ្ទង់
- សម្របសម្រួលការប្រើប្រាស់កម្មវិធី NSSF Benefit នៅ ប.ស.ស រាជធានី-ភ្នំពេញ និងសាខាខេត្ត/ខណ្ឌ
- សិក្សាបង្កើតតារាងសម្រាប់រក្សាទុកទិន្នន័យ របស់អ្នកទទួលបានធនលាភអចិន្ត្រៃយ៍ និងបង្កើតទម្រង់បញ្ចូល និងទាញព័ត៌មានមកវិញរបស់អ្នកទទួលបានធនលាភអចិន្ត្រៃយ៍

- បង្កើតទម្រង់គណនាប្រាក់ធនលាភបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ប្រចាំឆ្នាំ ដែលត្រូវកែសម្រួលតាមអតិផរណាមធ្យមប្រចាំឆ្នាំ
- បង្កើតទម្រង់បោះពុម្ពរបាយការណ៍កំហុសឆ្គងលើលទ្ធផលអង្កេតរបស់ខេត្ត/ខណ្ឌ
- បង្កើតទម្រង់បោះពុម្ពលើស្រោមសំបុត្រ, ទម្រង់បោះពុម្ពបញ្ជីឈ្មោះអ្នកបើកតាវ-កាលិក និងបង្កើតទម្រង់បោះពុម្ពសេចក្តីសម្រេចឡើងវិញ
- ធ្វើបច្ចុប្បន្នភាពរបាយការណ៍ប្រចាំខែ, ត្រីមាស, ឆមាស របស់អ្នកបាត់បង់សមត្ថភាព ការងារអចិន្ត្រៃយ៍ទៅតាមលក្ខខណ្ឌដែលគេចង់បាន
- ធ្វើបច្ចុប្បន្នភាពកម្មវិធីតាវកាលិក ដោយបន្ថែមទម្រង់បញ្ជូនរបាយការណ៍ហានិ-ភ័យការងារពីទីស្នាក់ការកណ្តាលទៅសាខា ប.ស.ស ខណ្ឌ/ខេត្ត, ទម្រង់របាយ-ការណ៍ចំណាយព្យាបាល វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យមិនជាប់កិច្ចសន្យា និងទម្រង់តាវកាលិកអចិន្ត្រៃយ៍ដោយទាញយក ប្រាក់បន្ថែមអតិផរណាមកបង្ហាញដោយស្វ័យប្រវត្តិ
- បង្កើតតារាងសម្រាប់ផ្ទុកទិន្នន័យ និងទម្រង់បញ្ចូលព័ត៌មានរបស់សិទ្ធិវន្តទទួលបានតាវកាលិកឧត្តរជីវី
- បង្កើតរបាយការណ៍ផ្សេងៗតាមតម្រូវការចាំបាច់របស់ការិយាល័យជំនាញ។

**កម្មវិធីបញ្ជិកា និងភាគទានៈ**

- ធ្វើបច្ចុប្បន្នភាពទម្រង់បង់ភាគទាន និងបង្កើតទម្រង់បិទរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍មួយចំនួន
- បន្ថែមទម្រង់ចុះបញ្ជិកាសមាជិក ប.ស.ស ថ្មី ដើម្បីភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យរបស់កម្មវិធីបញ្ជិកានិងភាគទាន និងបង្កើតកម្មវិធីដើម្បីធ្វើការសាកល្បងដំណើរការបង់ភាគទាន ក្នុងរបបថែទាំសុខភាពសម្រាប់ការិ.បញ្ជិកា និងភាគទាន
- រៀបចំរបាយការណ៍បង្ហាញចំនួនកម្មករនិយោជិត យោងតាមអាស័យដ្ឋានបច្ចុប្បន្ន និងរបាយការណ៍ចំនួនកម្មករនិយោជិតដែលប្រព័ន្ធផ្ទៀងផ្ទាត់ស្នាមម្រាមដៃ
- ធ្វើបច្ចុប្បន្នភាពទម្រង់បោះពុម្ពកាត និងទម្រង់បញ្ចូលលេខអត្តសញ្ញាណ ប.ស.ស និងទម្រង់បញ្ចូលប្រាក់បៀវត្សកម្មករនិយោជិតប្រចាំខែក្នុងរបបហានិភ័យការងារ
- រៀបចំបង្កើតកម្មវិធីបោះពុម្ពកាតជូនសមាជិក ប.ស.ស ថ្មី ដាច់ដោយឡែកពីកម្មវិធីបញ្ជិកា និងភាគទាន
- បច្ចុប្បន្នភាពទម្រង់ផ្ទៀងផ្ទាត់លេខអត្តសញ្ញាណ ប.ស.ស ដោយបង្ហាញពីតារាងកម្មករនិយោជិត ដែលមិនត្រឹមត្រូវពីខែមុនទម្រង់បញ្ចូលប្រាក់បៀវត្សរបស់កម្មករ-និយោជិត និងបន្ថែមមុខងារផ្ទៀងផ្ទាត់ Finger Print ក្នុងទម្រង់បញ្ចូលព័ត៌មានកម្មករនិយោជិតថ្មីក្នុងប្រព័ន្ធករណីមានទិន្នន័យស្ទួន
- បង្កើតរបាយការណ៍ផ្សេងៗតាមតម្រូវការចាំបាច់របស់ការិយាល័យជំនាញ។

**កម្មវិធីរដ្ឋបាល (NSSF Administration)៖** ធ្វើបច្ចុប្បន្នភាពលើទម្រង់គណនាប្រាក់ថែមម៉ោង, ទម្រង់បញ្ចូលប្រាក់ខែ និងទម្រង់គណនា វត្តមានប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំដោយឲ្យរំលងឈ្មោះណាដែលបានគណនារួច។

**កម្មវិធី NSSF Program (Web Application)៖**

- បន្ថែមទម្រង់គណនាចំនួនភាគទានសម្រាប់របបថែទាំសុខភាព
- បែងចែកការប្រើប្រាស់កម្មវិធីសម្រាប់របបហានិភ័យការងារ និងរបបថែទាំសុខ-ភាពនៅលើកម្មវិធីតែមួយ
- បង្កើតទម្រង់បញ្ជាក់ឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់មុននឹងអាចបញ្ជូនFile E-Form មកកាន់ Server
- បង្កើតទម្រង់សម្អាតព័ត៌មានកម្មករនិយោជិតម្តងបានទាំងអស់ចេញពី File E-Form
- កែតម្រូវ Error មួយចំនួនទាក់ទងនឹងការទាញទិន្នន័យកម្មករនិយោជិតដែលបានកំណត់អត្តសញ្ញាណថ្មីរបស់សហគ្រាសនីមួយៗ។

**កម្មវិធី NSSF Program៖**

- បានរៀបចំកម្មវិធី NSSF Program សម្រាប់របបថែទាំសុខភាពដើម្បីដាក់ឲ្យសហគ្រាសអាចចូលទៅទាញយកពីវេបសាយ និងបានធ្វើបទបង្ហាញស្តីពីរបៀបប្រើប្រាស់កម្មវិធីនេះផងដែរ
- ធ្វើបច្ចុប្បន្នភាពលើទម្រង់ប្រកាសកម្មករនិយោជិតលាឈប់ ពីការងារដើម្បីឲ្យមានភាពងាយស្រួលប្រើប្រាស់ជាងមុន ព្រមទាំងអនុញ្ញាតអាចឲ្យទាញយក File លាឈប់ដែលបានប្រកាសរួចហើយយកមកប្រកាសលាឈប់បន្ថែមទៀតបាន។

**កម្មវិធីប្រឡងតេស្តសមត្ថភាព៖**

- បង្កើត Database សម្រាប់ផ្ទុកទិន្នន័យវិញ្ញាសារ, ទម្រង់សម្រាប់បញ្ចូលសំណួរ និងកំណត់ចម្លើយត្រឹមត្រូវ និងទម្រង់សម្រាប់ចុះឈ្មោះបេក្ខជនប្រឡង
- បង្កើតទម្រង់សម្រាប់បេក្ខជនចូលប្រឡង និងកំណត់ពេលវេលាទៅតាមមុខវិជ្ជា, បង្កើតរបាយការណ៍បង្ហាញពិន្ទុរបស់បេក្ខជនតាមមុខវិជ្ជានីមួយៗ និងចំណាត់ថ្នាក់ដែលបេក្ខជនទទួលបានទៅតាមពិន្ទុ
- ធ្វើបច្ចុប្បន្នភាពលើទម្រង់ចុះឈ្មោះបេក្ខជន ដោយបន្ថែមព័ត៌មានដូចជាសញ្ញាបត្រ និងឯកទេស។

**កម្មវិធីអធិការកិច្ច៖**

- បង្កើតឈ្មោះអ្នកប្រើប្រាស់កម្មវិធីអធិការកិច្ចសម្រាប់មន្ត្រី និងបុគ្គលិកការិ.ប.ស.ស សាខាខេត្ត/ខណ្ឌ សម្រាប់ស្វែងរកទីតាំងសហគ្រាស និងដៅទីតាំងសហគ្រាសគ្រឹះស្ថានដោយប្រើផែនទី Google Map

- ធ្វើបច្ចុប្បន្នភាពទម្រង់សម្រាប់បញ្ចូលបណ្ដឹងសហគ្រាសគ្រឹះស្ថាន និងបន្ថែមឈ្មោះអ្នកប្រើប្រាស់ កម្មវិធីសម្រាប់មន្ត្រី និងបុគ្គលិកការិយាល័យសាខាខេត្ត/ខណ្ឌ។

**កម្មវិធីផ្ញើសារតាមរយៈ** Gateway (SMS Gateway) **សម្រាប់ផ្ញើសារជូនដំណឹងដល់សមាជិក ប.ស.ស៖**

- ធ្វើការសាកល្បងផ្ញើសារទៅកាន់ទូរស័ព្ទដៃតាមរយៈ Gateway
- បន្ថែម Function មួយចំនួន ដើម្បីធ្វើការទាញទិន្នន័យពីកម្មវិធីដូចជា៖
  - តាវកាលិក៖ សម្រាប់ជូនដំណឹងលទ្ធផលអង្កេតគ្រោះថ្នាក់ការងារ
  - បញ្ជិកា និងភាគទាន៖ សម្រាប់ជូនដំណឹងព័ត៌មានការបង់ភាគទាន និងសហគ្រាសដែលមិនទាន់បង់ភាគទាន
  - ស្វែងរកព័ត៌មានកម្មករនិយោជិតតាមរយៈទូរស័ព្ទចល័ត៖ សម្រាប់ផ្ញើលេខកូដប្រើប្រាស់ប្រព័ន្ធ។

**កម្មវិធីផ្ញើសារតាមរយៈ**Modem (SMS System) **សម្រាប់ទទួល និងឆ្លើយតបសារទៅកាន់ភ្នាក់ងារតាមមន្ទីរពេទ្យ៖** បង្កើត Function សម្រាប់ទាញទិន្នន័យរបស់សមាជិកក្នុងរបបថែទាំសុខភាព ដើម្បីបង្ហាញពីសុពលភាពក្នុងការប្រើប្រាស់សេវាតាមមន្ទីរពេទ្យ តាមរយៈការផ្ញើសារសាកសួរព័ត៌មានពីភ្នាក់ងារ ប.ស.ស ប្រចាំនៅមន្ទីរពេទ្យ។

**កម្មវិធីអង្កេតគ្រោះថ្នាក់ការងារបឋម៖**

- សិក្សាពី Flow ការងាររបស់ប្រព័ន្ធ និងរៀបចំ Design Interface របស់កម្មវិធី
- បង្កើត Database សម្រាប់ផ្ទុកទិន្នន័យ និងបង្កើតទម្រង់បញ្ចូលលិខិតប្រើប្រាស់សេវាសុខាភិបាល និងទម្រង់អង្កេតគ្រោះថ្នាក់ការងារបឋម
- កែសម្រួលទម្រង់បញ្ចូលរបាយការណ៍ហានិភ័យការងារ ដោយអាចឱ្យអ្នកប្រើប្រាស់បញ្ចូលរបាយការណ៍ហានិភ័យក្នុងករណីរួម និងដោយឡែកនៅលើទម្រង់តែមួយ។

**អភិវឌ្ឍន៍កម្មវិធីទាញទិន្នន័យ (NSSF Data Transfer)៖** សម្រាប់ការិយាល័យគណនេយ្យ ដើម្បីងាយស្រួលក្នុងការទាញយកទិន្នន័យភាគទានថែទាំសុខភាព និងទិន្នន័យចំណាយតាវកាលិក ដើម្បីដាក់ចូលក្នុងកម្មវិធី Sage Page របស់ការិយាល័យហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ។

**កម្មវិធីពិនិត្យសុពលភាពប្រើប្រាស់សេវានៅមន្ទីរពេទ្យតាមរយៈទូរស័ព្ទដៃប្រើប្រាស់ប្រព័ន្ធ Android៖**

- បង្កើតទីតាំងរក្សាទុកទិន្នន័យរបស់អ្នកប្រើប្រាស់កម្មវិធី និងទាញទិន្នន័យរបស់សមាជិកសម្រាប់ធ្វើការស្វែងរក
- រៀបចំទម្រង់ស្វែងរកព័ត៌មានសមាជិក ប.ស.ស
- ធ្វើបច្ចុប្បន្នភាពទម្រង់ស្វែងរកព័ត៌មានសមាជិក ប.ស.ស និងបន្ថែមកូដទាញទិន្នន័យរបស់សមាជិកសម្រាប់ធ្វើការស្វែងរក។

**កម្មវិធី HSPIS៖** ធ្វើការបញ្ចូលទិន្នន័យកម្មករនិយោជិត សម្រាប់ធ្វើការតេស្តសាកល្បងទៅក្នុងប្រព័ន្ធ HSPIS ដើម្បីផ្ទៀងផ្ទាត់សុពលភាពក្នុងការប្រើប្រាស់សេវាថែទាំសុខភាពតាមមន្ទីរពេទ្យនៃការបង់ភាគទានទៅតាមខែនីមួយៗ។

**៤.២.៣.២. ផ្នែក Networking**

- ដោះស្រាយបញ្ហាប្រព័ន្ធបណ្តាញនៅសាខា ប.ស.ស ខេត្តបន្ទាយមានជ័យ (ភ្ជាប់បណ្តាញបញ្ចូលគ្នា) រវាងសាខាសិរីសោភ័ណ និងសាខាប៉ោយប៉ែត) ដើម្បីទាញទិន្នន័យគ្រប់គ្រងវត្តមានមន្ត្រី និងបុគ្គលិក
- ចុះបេសកកម្មដំឡើងប្រព័ន្ធបណ្តាញបន្ថែម នៅការិយាល័យសាខាខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន
- សម្របសម្រួលត្រួតពិនិត្យដោះស្រាយប្រព័ន្ធនៅស្នាក់ការកណ្តាល និងសាខាខេត្ត
- សរសេរគោលការណ៍ព័ត៌មានវិទ្យា និងចូលរួមរៀបចំបណ្តាញជាថ្មីនៅសាខាខេត្តសៀមរាប
- សិក្សាបណ្តាញសម្រាប់តភ្ជាប់ពីមន្ទីរពេទ្យមកកាន់ទីស្នាក់ការកណ្តាល VPN (Layer 2+ Cisco ASA 5505)
- តភ្ជាប់ប្រព័ន្ធបណ្តាញបន្ថែមនៅសាខា ប.ស.ស ខេត្តកំពង់ធំ
- រៀបចំដំឡើងកម្មវិធីត្រួតពិនិត្យ GFI (រៀបចំដំឡើងម៉ាស៊ីនមេ)
- សហការជាមួយក្រុមហ៊ុន ECam ត្រួតពិនិត្យលើការធ្វើបច្ចុប្បន្នភាពអាជ្ញាប័ណ្ណបណ្តោះអាសន្នឧបករណ៍ Juniper
- ប្រជុំពិភាក្សាលើការរៀបចំធ្វើ DR (Data Recovery)
- សហការជាមួយក្រុមហ៊ុន Campura ដើម្បី Configure កម្មវិធីត្រួតពិនិត្យ GFI និង Troubleshooting Core Switch
- សហការរៀបចំបណ្តាញជាថ្មីម្តងទៀតនៅសាខា ប.ស.ស ខេត្តព្រះវិហារ
- សហការជាមួយក្រុមហ៊ុន Ecam Solution ដើម្បីរៀបចំបំបែក Public IP Address តាម Servers នីមួយៗ
- រៀបចំសាកល្បង Configuration Switch Cisco 2960x-Series
- តេស្តសាកល្បងបណ្តាញតភ្ជាប់ទៅកាន់ (DR) និងបណ្តាញតភ្ជាប់ទៅកាន់មន្ទីរពេទ្យ
- ដំឡើងប្រព័ន្ធបណ្តាញនៅសាខា ប.ស.ស ថ្មី (ផ្នែកថែទាំសុខភាព)
- ធ្វើការ Configure ក្នុង Juniper ដើម្បីកែប្រែ IP Address (Web Server, Email Server, DVR and SMS Gateway)
- រៀបចំឯកសារសម្រាប់ដំឡើងប្រព័ន្ធបណ្តាញនៅតាមមន្ទីរពេទ្យដៃគូ ប.ស.ស
- ដំឡើងតេស្តប្រព័ន្ធបណ្តាញនៅសាខាមន្ទីរពេទ្យ (កាល់ម៉ែត, ព្រះកុសុមៈ និងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត)

- សហការជាមួយក្រុមហ៊ុន Online ដើម្បីតភ្ជាប់ទៅកាន់គេហទំព័រធនាគារអេស៊ី-លីដា ឲ្យដំណើរការប្រក្រតីឡើងវិញក្រោយពីមានការផ្លាស់ប្តូរ IP Public ថ្មី
- ធ្វើការ Configure និងតេស្ត Cisco ASA 5505 សម្រាប់ដំឡើងតាមមន្ទីរពេទ្យ និងការិយាល័យអធិការកិច្ច (ក្បែរវត្តសំរោងអណ្តែត) ចំនួន ០៣ គ្រឿង
- ធ្វើការ Configure CiscoASA 5505 ដើម្បីភ្ជាប់ប្រព័ន្ធទូរស័ព្ទនៅការិយាល័យថែទាំសុខភាព ចំនួន០៣គ្រឿង
- ចុះបេសកកម្មត្រួតពិនិត្យប្រព័ន្ធនៅសាខា ប.ស.ស ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តព្រៃវែង និងខេត្តស្វាយរៀង
- បង្កើត VLAN ថ្មីសម្រាប់ដាក់ដំណើរការម៉ាស៊ីនមេ Finger Print និងConfigure Client ចំនួន ០៥ គ្រឿងអាចធ្វើការទំនាក់ទំនងទៅកាន់ម៉ាស៊ីនមេ Finger Print បាន។

### ៤.២.៣.៣. ផ្នែក Maintenance

- ទំនាក់ទំនងទៅគ្រប់បណ្តាខេត្ត និងខណ្ឌមួយចំនួន ដើម្បីសាកសួរអំពីដំណើរការកម្មវិធី ប.ស.ស និងប្រព័ន្ធបញ្ជូនទិន្នន័យប្រព័ន្ធអ៊ីនធើណេត និងដំណើរការកុំព្យូទ័រព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗ
- ដោះស្រាយបញ្ហា Error printer និង Network គ្រប់ការិយាល័យ នៅស្នាក់ការកណ្តាល និងសាខាខេត្ត-ខណ្ឌ
- ធ្វើការត្រួតពិនិត្យម៉ាស៊ីនត្រជាក់ សីតុណ្ហភាព ប្រព័ន្ធអគ្គីសនីនៅក្នុងបន្ទប់ Server និងត្រួតពិនិត្យប្រព័ន្ធដំណើរការរបស់ម៉ាស៊ីន Server ជារៀងរាល់សប្តាហ៍
- ត្រួតពិនិត្យនៅលើ Antivirus Server និងធ្វើការ Scan Virus នៅលើកុំព្យូទ័រគ្រប់ការិយាល័យទីស្នាក់ការកណ្តាល។
- សហការរវាងផ្នែកតំហែទាំ និងផ្នែកណែតវើក ដើម្បីដោះស្រាយបញ្ហាដាច់ប្រព័ន្ធ Wifi ឱ្យដំណើរការឡើងវិញ
- បង្កើតវីដេអូបង្រៀនពីរបៀបប្រើប្រាស់ប្រព័ន្ធទម្រង់ចុះលេខរបាយការណ៍ហានិភ័យការងារនៃការិ.តាវកាលិក និងបង្រៀនពីរបៀបប្រើប្រាស់ប្រព័ន្ធ (ទម្រង់ពិនិត្យ និងផ្ទៀងផ្ទាត់កំណត់បង្ហាញអង្កេត (Post) និងទម្រង់ពិនិត្យ និងយល់ព្រមកំណត់បង្ហាញអង្កេត (Submit) នៃការិ.អធិការកិច្ច និងកិច្ចការនីតិកម្ម
- សហការជាមួយក្រុមហ៊ុនទូរស័ព្ទ ដើម្បីដំឡើងស្តង់ដាទូរស័ព្ទថ្មីមួយគ្រឿងបន្ថែមទៀត
- សហការជាមួយក្រុមហ៊ុន Internet Online ដើម្បីតេស្តប្រព័ន្ធបញ្ជូនទិន្នន័យនៅសាខា ប.ស.ស ខេត្តកំពង់ឆ្នាំង
- ទំនាក់ទំនងទៅកាន់ក្រុមហ៊ុនទូរស័ព្ទ ដើម្បីជួយដោះស្រាយបញ្ហាលេខទូរស័ព្ទ ០២៣ ដែលបានដាច់ ព្រមទាំងបានកែនូវប្រព័ន្ធលើឧបករណ៍ System ទូរស័ព្ទ

ដើម្បីដោះស្រាយបញ្ហាជាបណ្តោះអាសន្នទៅលើប្រព័ន្ធទូរស័ព្ទ ដែលប្រើប្រាស់ក្នុង ប.ស.ស

- សហការជាមួយក្រុមហ៊ុនដោះស្រាយម៉ាស៊ីន GMS Display នៅលើអេក្រង់ទូរទស្សន៍ នៅការិ.បញ្ជិកា និងភាគទាន
- សហការជាមួយក្រុមហ៊ុន Symantec ដើម្បីដោះស្រាយបញ្ហា Symantec Client មិនទាញយក Update Definition ពី Symantec Sever
- ធ្វើការ Upgrade Windows System ពី32bit ទៅ 64bit គ្រប់ការិ.ស្នាក់ការកណ្តាល និងការិ.សាខាខេត្ត-ខណ្ឌ។

### ៤.២.៤. ការងារសវនកម្មផ្ទៃក្នុង

ក្នុងន័យលើកកម្ពស់ប្រសិទ្ធិភាពរបស់គ្រឹះស្ថាន សវនកម្មផ្ទៃក្នុងបានទទួលអនុវត្តចង្កោមសកម្មភាពទី០៥ "ការអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង" មានសកម្មភាពចំនួន ០៣គឺ៖

- សកម្មភាពទី១ ៖ ពង្រឹង និងពង្រីកអភិបាលកិច្ចសវនដ្ឋានផ្ទៃក្នុង
- សកម្មភាពទី២ ៖ គ្រប់គ្រងធនធានមនុស្សរបស់សវនកម្មផ្ទៃក្នុង
- សកម្មភាពទី៣ ៖ ពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង

ជាមួយគ្នានោះ សវនករសម្រេចបានសកម្មភាពទី១ និងសកម្មភាពទី៣ ដោយបានធ្វើសវនកិច្ចនៅតាមបណ្តាការិយាល័យបេឡាជាតិរបបសន្តិសុខសង្គម សាខាខេត្ត បានចំនួន២០ សាខាខេត្ត លើការគ្រប់គ្រងទ្រព្យសម្បត្តិការគ្រប់គ្រងប្រតិបត្តិការ និងការគ្រប់គ្រងចំណាយរបស់សាខាខេត្តនីមួយៗ អនុវត្តប្រភេទសវនកម្ម "ក្នុងនោះបានរកឃើញចំណុចខ្វះខាត និងបានផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្ម ព្រមទាំងរាយការណ៍ជូននាយកគ្រឹះស្ថាន និងបានត្រួតពិនិត្យការអនុវត្តន៍អនុសាសន៍សវកម្ម បានចំនួន០៩ សាខាខេត្ត។

### ៤.២.៥. គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទ ឬ បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង ប.ស.ស ដែលគណៈកម្មការនេះមានការចូលរួមត្រីភាគីរួមមានតំណាង ប.ស.ស តំណាងនិយោជក និងកម្មករនិយោជិត។

សម្រាប់ឆ្នាំ២០១៦ នេះ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស បានប្រជុំផ្ទៃក្នុងចំនួន ០១លើក ដោះស្រាយចំនួន ០២លើក ដូចខាងក្រោម៖

- ពិនិត្យលើលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០១៦ របស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស
- ពិនិត្យលើលទ្ធផលករណីវាយតម្លៃគ្រោះថ្នាក់ការងារទៅលើកម្មការិនី ឈ្មោះ យន់ សម្បត្តិ បម្រើការងារនៅសហគ្រាស NAGAPEACE CORP ORANTION LIMITED
- ពិនិត្យមើលលើបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ១១-១៦ ប.ស.ស/ជ.វ.ប ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៦ របស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស។

## ៤.៣. ការងារប្រជុំផ្សព្វផ្សាយ និងបង្ការហានិភ័យការងារ

ការងារផ្សព្វផ្សាយជាការងារមួយដ៏សំខាន់ ដែល ប.ស.ស បានយកចិត្តទុកដាក់ខ្ពស់ដោយក្នុងនោះបានរៀបចំនូវផែនការផ្សព្វផ្សាយសាធារណៈជាច្រើន ដើម្បីផ្សព្វផ្សាយពីលទ្ធផលសម្រេចបាន, ការងារបង្ការគ្រោះថ្នាក់ការងារ, ការអនុវត្តគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ក៏ដូចជាការពង្រឹងការអនុវត្តបន្ថែមជាមួយផ្នែកពាក់ព័ន្ធរួមមាននិយោជក, តំណាងកម្មករនិយោជិត, អង្គការសហជីព, អង្គភាពផ្តល់សេវាសុខាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដើម្បីឱ្យទទួលបានព័ត៌មានថ្មីៗពីការអនុវត្តគោលនយោបាយសន្តិសុខសង្គម និងឱ្យមានការចូលរួមផ្សព្វផ្សាយ និងទប់ស្កាត់-ហានិភ័យការងារទាំងអស់គ្នា។ ជាការគួរឱ្យកត់សំគាល់នៅឆ្នាំ២០១៦ ការងារផ្សព្វផ្សាយមួយចំនួនត្រូវបានអនុវត្តដូចខាងក្រោមៈ

- ប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៥ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦ របស់ ប.ស.ស នៅសាលប្រជុំបេឡាជាតិរបបសន្តិសុខសង្គម។
- ប្រជុំផ្សព្វផ្សាយលទ្ធផលការងារសម្រេចបានឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៦ របស់ក្រុមការងារ ទ.ស.ប.ក និងក្រុមការងារ ស.ផ.ក។
- ប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងសេវានៃការផ្តល់តាវកា-លិកហានិភ័យការងារ។
- ប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព
- ប្រជុំផ្សព្វផ្សាយស្តីពីលក្ខខណ្ឌអនាម័យ, សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ, អត្ថប្រយោជន៍របបសន្តិសុខសង្គម,វិធានការទប់ស្កាត់ករណីសន្លប់ និងមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត។
- ប្រជុំផ្សព្វផ្សាយស្តីពី ការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនដល់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត, វគ្គបណ្តុះបណ្តាល និងប្រឡងយកបណ្ណបើកបរ។
- ប្រជុំផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីសន្លប់, គ្រូបង្គោលអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, គ្រូបង្គោលភ្នាក់ងារសង្គ្រោះបឋម។
- ផ្សព្វផ្សាយស្ព័តរូបភាពតាមស្ថានីយទូរទស្សន៍ និងស្ព័តសំលេងតាមវិទ្យុ។

*រូបភាពទី៣. ពិធីផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព*





- ព្រឹត្តិបត្រ, ប្រតិទិន, ខិត្តប័ណ្ណ, សៀវភៅផ្សព្វផ្សាយ និងឯកសារចុះបញ្ជិកា ត្រូវបានចែកជូនដល់អ្នកចូលរួមក្នុងកម្មវិធីនីមួយៗ។

ក្រៅពីការងារផ្សព្វផ្សាយខាងលើ ប.ស.ស ក៏មានគេហទំព័រ (www.nssf.gov.kh) ដែលផ្ទុកនូវរាល់ព័ត៌មាន និងឯកសារគតិយុត្តសំខាន់ៗទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងមានបណ្តាញទំនាក់ទំនងសង្គម *(Page Facebook បេឡាជាតិរបបសន្តិសុខសង្គម www.facebook.com/nssfpage)*, ប្រព័ន្ធទូរស័ព្ទ និងទំនាក់ទំនងបន្ទាន់ Hot Line ១២៨៦ ដែលបានផ្សព្វផ្សាយនូវព័ត៌មានទាន់ហេតុការណ៍នានា ទាក់ទងនឹងការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងអាចផ្តល់ព័ត៌មានផ្ទាល់ជាមួយនឹងសមាជិកភ្លាមៗ។ មួយវិញទៀត ប.ស.ស ក៏បានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតជាច្រើនផងដែរ និងបានចាត់បញ្ជូនមន្ត្រីឱ្យចុះធ្វើការផ្សព្វផ្សាយ ពន្យល់ណែនាំដល់បណ្តាសហគ្រាស គ្រឹះស្ថាន ផ្ទាល់ជាពិសេសការអនុវត្តគោលនយោបាយផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកា, ការបង់ភាគទាន និងទាមទារ/ផ្តល់តាវកាលិក (អត្ថប្រយោជន៍) ដែលកម្មករនិយោជិតត្រូវទទួលបាន។

### ៤.៣.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម

ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម បានធ្វើការផ្សព្វផ្សាយស្តីពីគោលនយោបាយនៃការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ឆ្នាំ២០១៦ នេះ បានធ្វើការប្រជុំផ្សព្វផ្សាយជូនដល់តំណាងសហគ្រាស គ្រឹះស្ថាន ជនរងគ្រោះដែលជាសមាជិក ប.ស.ស តំណាងអង្គភាព មន្ទីរ អាជ្ញាធរមានសមត្ថកិច្ច មូលដ្ឋានផ្តល់សេវាសុខាភិបាល (ចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស) ព្រមទាំងជនរងគ្រោះទាំងអស់ ដែលកំពុងទទួលបានតាវកាលិកហានិភ័យការងារពី ប.ស.ស មកចូលរួមប្រជុំ។

**តារាងទី ២២៖ ការងារផ្សព្វផ្សាយ គោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម**

| ការងារផ្សព្វផ្សាយ គោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម | | | | | |
|---|---|---|---|---|---|
| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
| | លើក | និយោជក/សហជីព/ជនរងគ្រោះ/អាជ្ញាធរ | រាជធានី-ខេត្ត | សរុប | ស្រី |
| ឆ្នាំ2016 | 74 | 12,868 | 30 | 12,868 | 5,274 |
| ឆ្នាំ2015 | 46 | 4,841 | 24 | 6,188 | 2,475 |
| បម្រែបម្រួល (± %) | +60.87% | +165.81% | +25.00% | +107.95% | +113.09% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ2016

**តារាងទី ២២.១៖ ផ្សព្វផ្សាយ ផ្នែកហានិភ័យការងារ**

| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|---|
| | លើក | និយោជក/សហជីព/ជនរងគ្រោះ/អាជ្ញាធរ | រាជធានី-ខេត្ត | សរុប | ស្រី |
